គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក

G B MICROFINANCE INSTITUTION PLC.

# របាយការណ៍ប្រចាំឆ្នាំ ២០២០


អាគារ ចេ៣៧ ផ្លូវលំ សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ

០២៣ ៩៧៧ ៧៧៨/ ០៩៩ ៩៧០ ៥៥៥

info@gbmfi.com.kh

www.gbmfi.com.kh

www.facebook.com/gbmicrofinance

# មាតិកា


១ សារតាររបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ........ ០១
២ ចំណាប់អារម្មណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល ........ ០២
៣ សាររបស់នាយកប្រតិបត្តិ ........ ០៣
៤ ទស្សនវិស័យរបស់គ្រឹះស្ថាន ........ ០៤
៥ បេសកកម្មរបស់គ្រឹះស្ថាន ........ ០៥
៦ តម្លៃស្នូលរបស់គ្រឹះស្ថាន ........ ០៦
៧ រចនាសម្ព័ន្ធរបស់គ្រឹះស្ថាន ........ ០៧
៨ គណៈគ្រប់គ្រង ........ ០៨
៩ ដៃគូអាជីវកម្ម ........ ១៥
១០ អតិថិជនរបស់យើង ........ ១៦
១១ កម្មវិធីបណ្តុះបណ្តាលនិងការអភិវឌ្ឍបុគ្គលិក ........ ១៧
១២ កម្រងអនុស្សាវរីយ៍នៃក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង បុគ្គលិក និងអតិថិជន ........ ១៩
១៣ វិញ្ញាបនបត្រ និងសមាជិកភាព ........ ២០


*របាយការណ៍របស់ក្រុមប្រឹក្សាភិបាល*


១៤ របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ........ ២១
១៥ របាយការណ៍របស់សវនករឯករាជ្យ ........ ២៤


*របាយការណ៍សវនកម្មស្តីអំពីរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ២០២០។*


១៦ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២០ ........ ២៩
១៧ របាយការណ៍លទ្ធផលពេញលេញ ........ ៣០
១៨ របាយកាណ៍បំរែបំរួលមូលធន ........ ៣១
១៩ របាយការណ៍បំរែបំរួលសាច់ប្រាក់ ........ ៣២
២០ កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ........ ៣៤


*គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក។ ព័ត៌មានហិរញ្ញវត្ថុបន្ថែមនិងកំណត់សម្គាល់ដែលតម្រូវដោយធនាគារជាតិ នៃ កម្ពុជា ។ (នេះមិនមែនជាផ្នែកនៃរបាយការណ៍សវនកម្មទេ)។*


២១ សេចក្តីប្រកាសរបស់ក្រុមប្រឹក្សាភិបាល ........ ៧៥
២២ មូលនិធិផ្ទាល់សុទ្ធ ........ ៧៦
២៣ អនុបាតសោធនភាព ........ ៧៧
២៤ អនុបាតសាច់ប្រាក់ងាយស្រួល ........ ៧៨
២៥ ចំណាត់ថ្នាក់ឥណទាននិងសំវិធានធនសម្រាប់ឥណទានជាប់សង្ស័យ និងបាត់បង់ ........ ៧៩
២៦ ការគណនាស្ថានភាពចំហរសុទ្ធនៃរូបិយប័ណ្ណ ........ ៨០
២៧ សេចក្តីសង្ខេបនៃរបាយការណ៍ ........ ៨១

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក

## ការិយាល័យកណ្តាលៈ ទីក្រុងកោះពេជ្រ រាជធានីភ្នំពេញ



គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ត្រូវបានបង្កើតឡើងដោយ លោក តាំង គួងហាវ និង លោកស្រី HSU, CHIA-CHIA ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងមានការិយាល័យកណ្តាលនៅរាជធានីភ្នំពេញ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក បានទទួលវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មលេខ០០០៨៣៩០៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ចេញដោយក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ត្រូវបានផ្តល់អាជ្ញាបណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដោយធនាគារជាតិ នៃ កម្ពុជា លេខ ម.ហា ៩២ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក បានក្លាយជាសមាជិកនៃសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា(CMA) ដែលមានវិញ្ញាបនបត្រសមាជិក លេខ ១២២/ ២០ស៊ីអឹមអេ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ ២០២០។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក សូមសាទរចូលរួមចំណែកយ៉ាងសកម្មក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ដែលមានប្រាក់ចំណូលពីកម្រិតទាបឡើងទៅនៅក្នុងប្រទេស និងគាំទ្រដល់ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតង ឆ្នាំ២០១៣-២០៣០។

# សាររបស់ប្រធានក្រុមប្រឹក្សាភិបាល

## លោក តាំង គួងបាវ
ប្រធានក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក



គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ផ្តល់ជូនលោកអ្នកនូវដំណោះស្រាយហិរញ្ញវត្ថុដ៏ពេញចិត្ត។

យើងផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុ ដែលមានគុណភាពខ្ពស់ និងអាចជឿទុកចិត្តបានដល់អតិថិជនដែលមានប្រវត្តិឥណទានល្អ មុខរបរស្របច្បាប់ និងសមត្ថភាពក្នុងការទូទាត់សង។

យុទ្ធសាស្ត្រអាជីវកម្មរបស់យើងគឺ នាំមកនូវគុណតម្លៃដល់សហគមន៍ និងផ្តល់ជូនអតិថិជននូវផលិតផលហិរញ្ញវត្ថុដែលអតិថិជនត្រូវការប្រកបដោយភាពស្មោះត្រង់ និងទុកចិត្ត។

គណៈគ្រប់គ្រងរបស់យើងត្រូវបានផ្តួចផ្តើមឡើងដោយកិច្ចសហប្រតិបត្តិការមួយ នៅឆ្នាំ២០២០ រវាងក្រុមហ៊ុនកម្ពុជា និងតៃវ៉ាន់ និងត្រូវបានបើកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីលើកទឹកចិត្តអតិថិជននៅកម្ពុជាយើង ក្នុងការទទួលបាននូវប្រាក់កម្ចីទិញគេហដ្ឋាន និងវីឡាដែលមានទំហំកម្ចីរហូតដល់១០០% (មួយរយភាគរយ) នៃតម្លៃគេហដ្ឋានដែលត្រូវបានប្រើប្រាស់ចំពោះគម្រោងអភិវឌ្ឍផ្ទះ និងវីឡារបស់ដៃគូជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក យើងខ្ញុំ។

សូមអរគុណចំពោះការចំណាយពេលដ៏មានតម្លៃរបស់អ្នកក្នុងការអានរបាយការណ៍ប្រចាំឆ្នាំ និងការចូលមើលគេហទំព័ររបស់យើងខ្ញុំ។ សូមសំណាងល្អ និងរីករាយឆ្នាំថ្មី។

សូមអរគុណ!

# សាររបស់នាយកប្រតិបត្តិ



តំណាងឱ្យគណៈគ្រប់គ្រងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ខ្ញុំសូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅ ចំពោះ សម្តេច ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី នាង កញ្ញា និងអតិថិជនជាទីស្រឡាញ់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃអានរបាយការណ៍ប្រចាំឆ្នាំ និងបានផ្តល់/ទទួលសេវាកម្មជាមួយស្ថាប័នរបស់យើងខ្ញុំ។

បច្ចុប្បន្ននេះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺជាផ្នែកមួយនៃអង្គភាពសេដ្ឋកិច្ច និងជាអន្តរការីហិរញ្ញវត្ថុ ដើម្បីជួយដល់ប្រជាជនចំពោះតម្រូវការដំណោះស្រាយផ្នែកហិរញ្ញវត្ថុនៅក្នុងប្រទេស។ ខ្ញុំមានសេចក្តីរីករាយណាស់ ដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក បានចាប់ផ្តើមប្រតិបត្តិការក្នុងនាមជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនាដើមខែវិច្ឆិកា ឆ្នាំ២០១៩ កន្លងមកនេះ។

គ្រឹះស្ថានយើងមានបំណងធ្វើឱ្យប្រសើរឡើងឥតឈប់ឈរនូវការផ្តល់សេវាកម្មហិរញ្ញវត្ថុ និងការច្នៃប្រឌិតសេវាកម្មល្អៗរបស់យើងជូនដល់អតិថិជន ដោយលើកទឹកចិត្តដល់អតិថិជនបង្កើនទ្រព្យសម្បត្តិឱ្យប្រសើរជាងមុនតាមរយៈដំណោះស្រាយហិរញ្ញវត្ថុ និងលើកកម្ពស់សេវាកម្មហិរញ្ញវត្ថុក្នុងដំណើរការរយៈពេលវែងជាមួយគ្រឹះស្ថានរបស់យើងខ្ញុំ។ ម្ចាស់ភាគហ៊ុននៃគ្រឹះស្ថានយើងខ្ញុំនៅប្រទេសកម្ពុជា និងតៃវ៉ាន់ បានរួមចំណែកក្នុងផ្នែកសេវាកម្មហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍស្ថានភាពរស់នៅរបស់ប្រជាជនចាប់ពីកម្រិតចំណូលទាបឡើងទៅ និងដើម្បីគាំទ្រដល់ផែនការអភិវឌ្ឍន៍ប្រទេសរបស់រដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអតិថិជនដែលកំពុងប្រើសេវាកម្ម និងមានគម្រោងប្រើសេវាកម្មហិរញ្ញវត្ថុរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក នៅថ្ងៃអនាគត ដើម្បីទទួលបានកំណើនសេដ្ឋកិច្ចក្នុងគ្រួសារ។

ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអាជ្ញាធរគ្រប់លំដាប់ថ្នាក់ រួមទាំងធនាគារជាតិ នៃ កម្ពុជា ដែលបានសហការ និងគាំទ្រដល់គ្រឹះស្ថានយើងខ្ញុំ ក្នុងការគ្រប់គ្រងដំណើរការល្អប្រសើរ និងតម្លាភាពដល់អតិថិជនរបស់យើងហើយនឹងបន្តទៅអនាគត។

សូមជូនពរ សូមទទួលបានជោគជ័យ សុភមង្គល និងបានសុខចម្រើនគ្រប់ៗគ្នា។ ដោយក្តីគោរពពីខ្ញុំ !

**ជេដ្ឋ គីមជិន**

នាយកប្រតិបត្តិ

គ្រឹះស្ថាននឹងត្រូវបានទទួលស្គាល់ពេញផ្ទៃប្រទេស ថាជាគ្រឹះស្ថានដ៏ធំមួយក្នុង
ចំណោមគ្រឹះស្ថានធំៗផ្នែកខាងប្រាក់កម្ចីគេហដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មានជំនាញនិងចំណេះដឹងខ្ពស់នៅក្នុងវិស័យឥណទានគេហដ្ឋាន។

បង្កើតស្តង់ដារថ្មីជាបន្តបន្ទាប់ដើម្បីអភិវឌ្ឍសេវាកម្មប្រាក់កម្ចីគេហដ្ឋានក្នុងប្រទេស។

ប្រតិបត្តិការតាមប្រព័ន្ធអ៊ីនធឺណេត និងប្រើប្រាស់បច្ចេកវិទ្យាទំនើបដើម្បីផ្តល់ការអនុម័តនិងការទូទាត់ផ្នែកហិរញ្ញវត្ថុបានឆាប់រហ័ស។

## សោមនស្សរីករាយក្នុងការលើកទឹកចិត្តអតិថិជននិងដៃគូក្នុងការបង្កើនទ្រព្យសម្បត្តិ ៖

- រក្សាភាពងាយស្រួល មានលក្ខខណ្ឌតាមច្បាប់ អតិថិជនអាចទទួលបានការអនុម័តឥណទានបានឆាប់រហ័ស។
- ផ្តល់សេវាដោយឥតគិតថ្លៃសម្រាប់ ការពិគ្រោះយោបល់ផ្នែកច្បាប់ដើម្បីទទួលបានភាពជាម្ចាស់កម្មសិទ្ធអចលនទ្រព្យ។
- %
- សម្រួលការបង់ប្រាក់បត់បែនទាំងលើការប្រាក់ និងប្រាក់ដើមសម្រាប់អតិថិជន។
- ចែករំលែកអត្ថប្រយោជន៍ដល់អ្នកពាក់ព័ន្ធ អតិថិជន និងដៃគូ។

## ប្រតិបត្តិការប្រកបដោយក្រមសីលធម៌ ដើម្បីជាប្រយោជន៍ដល់សហគមន៍ ៖

- គាំទ្រផ្នែកលំនៅដ្ឋានដល់យុវជនដែលបានចាប់ផ្តើមបង្កើតក្រុមគ្រួសារថ្មី ។
- ផ្តល់ការប្រឹក្សាដោយឥតគិតថ្លៃដើម្បីទទួលបានប្រាក់កម្ចីគេហដ្ឋាន។
- ផ្តល់អាទិភាពឱ្យបុគ្គលិកផ្ទៃក្នុងនូវឱកាសឋានៈការងារនិងទទួលបានអត្ថប្រយោជន៍មុនបុគ្គលិកមានប្រភពពីខាងក្រៅ។
- ជួយមនុស្សពេញវ័យដែលកំពុងស្វែងរកបទពិសោធន៍ការងារឱ្យមានឱកាស។
- លើកកម្ពស់ការអនុវត្ត និងការប្រកួតប្រជែងល្អនៅក្នុងឧស្សាហកម្មប្រាក់កម្ចីគេហដ្ឋាន។




គោលបំណងនៃការធ្វើយុទ្ធសាស្ត្រ គឺត្រូវអនុវត្តតាមតម្លៃស្នូលដែលបានតាក់តែងឡើង ដើម្បីបង្កើតវិធីសាស្ត្រគ្រប់គ្រង អភិវឌ្ឍន៍ដោយរក្សានូវការជឿទុកចិត្តពីគ្រប់មជ្ឈដ្ឋាន និងតាមកាលៈទេសៈ។

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក**

**G B MICROFINANCE INSTITUTION PLC.**

# វចនាសម្ព័ន្ធគ្រប់គ្រង




ការិយាល័យកណ្តាល: អគារលេខ ចេ៣៧, ផ្លូវលំ, សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា។
ទូរស័ព្ទលេខ:(+៨៥៥) ២៣ ៩៧៧ ៧៧៨/៩៩ ៥៧០ ៥៥៥, www.gbmfi.com.kh, E-mail: info@gbmfi.com.kh
Facebook Page: facebook.com/gbmicrofinance

## លោក ជេដ្ឋ គីមជិន
### នាយកប្រតិបត្តិ



លោក ជេដ្ឋ គីមជិន បានចូលបំរើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ក្នុងខែកញ្ញា ឆ្នាំ២០១៩ ក្នុងតួនាទីជានាយកប្រតិបត្តិ ដែលលោកត្រូវបានទទួលស្គាល់ដោយធនាគារជាតិ នៃ កម្ពុជា។ លោក ជេដ្ឋ គីមជិន មានបទពិសោធន៍ និងចំណេះដឹងនៅក្នុងឧស្សាហកម្មសេវាកម្មហិរញ្ញវត្ថុរយៈពេលជាង២០ឆ្នាំលើសមត្ថភាពផ្សេងៗគ្នារួមមាន ៖ ការអភិវឌ្ឍអាជីវកម្ម ទីផ្សារនិងការលក់ ការគ្រប់គ្រងឥណទាន ការគ្រប់គ្រងធនាគារនិងហិរញ្ញវត្ថុ។

លោក ជេដ្ឋ គីមជិន ធ្លាប់បានចូលបំរើការងារផ្នែក សេវាកម្មហិរញ្ញវត្ថុ នៅធនាគារពាណិជ្ជ នាឆ្នាំ១៩៩៩ ហើយបន្ទាប់មក លោកត្រូវបានជ្រើសតាំងជាប្រធានសាខានៃធនាគារពាណិជ្ជនៅឆ្នាំ២០០៧។ ឆ្នាំ២០១៨ លោកបានក្លាយជា នាយកប្រតិបត្តិ នៃក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅភ្នំពេញតរៀងមក។

លោក ជេដ្ឋ គីមជិន បានទទួលបរិញ្ញាបត្រផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ចពីវិទ្យាស្ថានអន្តរជាតិនៃកម្ពុជាក្នុងឆ្នាំ២០០៣ និងអនុបណ្ឌិតផ្នែកហិរញ្ញវត្ថុ និងធនាគារពីវិទ្យាស្ថានអន្តរជាតិសិង្ហបុរីនៅកម្ពុជាក្នុងឆ្នាំ២០០៦។

លោកបានទទួលលិខិតបញ្ជាក់ អំពីការសិក្សាវគ្គជំនាញ វគ្គបំប៉ន សិក្ខាសាលាជាច្រើនផ្សេងទៀតដែលទាក់ទងនឹងវិស័យសេវាកម្មហិរញ្ញវត្ថុ ឧស្សាហកម្មពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជា។ លើសពីនេះ លោកបានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាមួយចំនួនទាក់ទងនឹងសេវាកម្មហិរញ្ញវត្ថុ ធនាគារ និងពាណិជ្ជកម្មអន្តរជាតិនៅប្រទេសចិន ម៉ាឡេស៊ី ថៃ និងប្រទេសវៀតណាមផងដែរ។

## អ្នកស្រី ប្អូន ច័ន្ទសុភា
### ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ



អ្នកស្រី ប្អូន ច័ន្ទសុភា មានបទពិសោធន៍ការងាររយៈពេលជាង១៨ឆ្នាំ ផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ រួមមាន១២ឆ្នាំ បានបម្រើការងារនៅធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

អ្នកស្រី ធ្លាប់ជាគណនេយ្យករម្នាក់បម្រើការងារ នៅអង្គការក្រៅរដ្ឋាភិបាលក្នុងឆ្នាំ២០០៨។

បន្ទាប់មក អ្នកស្រីបានចូលបម្រើការងារនៅធនាគារ អេស៊ីលីដា ភីអិលស៊ី នាឆ្នាំ២០០៧ ជាគណនេយ្យកររយៈពេល ៩ឆ្នាំ។ អ្នកស្រីបានចូលបម្រើការងារនៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី ក្នុងមុខងារជាប្រធានគណនេយ្យករនៅឆ្នាំ២០១៦ និងត្រូវបានដំឡើងតួនាទីជាប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៅក្នុងខែវិច្ឆិកា ឆ្នាំ ២០១៧។

អ្នកស្រី ប្អូន ច័ន្ទសុភា មានជំនាញក្នុងវិស័យហិរញ្ញវត្ថុដូចជា ការរៀបចំផែនការគម្រោងហិរញ្ញវត្ថុ ផែនការអាជីវកម្ម និងការវិភាគថវិកា។ អ្នកស្រីជាអ្នកជំនាញផ្នែក ការងារប្រកាសពន្ធទៅអគ្គនាយកដ្ឋានពន្ធដារកម្ពុជា ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ធនាគារជាតិ នៃ កម្ពុជា និងរៀបចំរបាយការណ៍សម្រាប់ក្រុមប្រឹក្សាភិបាល និងម្ចាស់ភាគហ៊ុន។ លើសពីនេះទៅទៀត អ្នកស្រីក៏ជាអ្នកជំនាញផ្នែកអភិវឌ្ឍន៍គោលនយោបាយ និងនីតិវិធីហិរញ្ញវត្ថុ និងគណនេយ្យសម្រាប់គ្រឹះស្ថានផងដែរ។

អ្នកស្រី ប្អូន ច័ន្ទសុភា បានបញ្ចប់ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម ជំនាញគណនេយ្យ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង នៃ កម្ពុជា (NUM) នៅក្នុងឆ្នាំ២០០៦ ហើយអ្នកស្រី បានទទួលសញ្ញាបត្រជាន់ខ្ពស់ភាសាអង់គ្លេស ពីសាកលវិទ្យាល័យបញ្ញាសាស្ត្រ នៃ កម្ពុជា នៅឆ្នាំ២០១២។ លើសពីនេះទៀត អ្នកស្រីបានចូលរួមវគ្គសិក្សា និងសិក្ខាសាលាជាច្រើនទាក់ទងនឹងកិច្ចការធនាគារ និងមីក្រូហិរញ្ញវត្ថុទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ។

បច្ចុប្បន្នអ្នកស្រី បានចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ក្នុងមុខតំណែងជាប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ក្នុងខែកញ្ញា ឆ្នាំ២០១៩ ។

## លោក ជួន ពិសិដ្ឋ
### ប្រធាននាយកដ្ឋានរដ្ឋបាលនិងធនធានមនុស្ស

លោក ជួន ពិសិដ្ឋ បានទទួលបរិញ្ញាបត្រភាសាអង់គ្លេស នៅឆ្នាំ២០០៧និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងធុរកិច្ច ពាណិជ្ជកម្ម ជំនាញគ្រប់គ្រងទូទៅក្នុងឆ្នាំ២០១១ ពីសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ(PPIU)។



លោក ជួន ពិសិដ្ឋ ក៏បានចូលរួមវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលាជាច្រើនដូចជា ការគ្រប់គ្រងការប្រតិបត្តិការងាររបស់និយោជិត ជំនាញទន់សម្រាប់អ្នកគ្រប់គ្រងថ្នាក់កណ្តាល ការគ្រប់គ្រងវិបត្តិព័ត៌មាននិងកម្មវិធីប្រតិបត្តិការយោធាស៊ីវិល និងភ្នាក់ងារថាមពលអាតូមិកអន្តរជាតិ បច្ចេកទេសស៊ើបអង្កេត ការលាងលុយកខ្វក់ និងជំនាញស៊ើបអង្កេតហិរញ្ញវត្ថុ ពីគណៈកម្មាធិការជាតិ SNCTC និងស្ថានទូតអាមេរិកពីឆ្នាំ២០១១ រហូតដល់ឆ្នាំ២០១៨។

លោក ជួន ពិសិដ្ឋ បានចូលបំរើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ក្នុងមុខតំណែងជាប្រធាននាយកដ្ឋានរដ្ឋបាលនិងធនធានមនុស្សនៅខែកញ្ញា ឆ្នាំ២០១៩។

លោក ជួន ពិសិដ្ឋ មានបទពិសោធន៍ការងារជាង១៣ឆ្នាំ លើការងារប្រតិបត្តិការ រដ្ឋបាល ធនធានមនុស្ស និងជាសាស្ត្រាចារ្យ ដោយរាប់បញ្ចូលទាំង៨ឆ្នាំបានបម្រើការងារនៅគ្រឹះស្ថានហិរញ្ញវត្ថុ និង៨ឆ្នាំ បម្រើការងារនៅសាកលវិទ្យាល័យលំដាប់ទី៨នៅភ្នំពេញ។

លោកក៏ធ្លាប់ជាមន្ត្រីអង្គការអន្តរជាតិក្រៅរដ្ឋាភិបាល នៅកម្ពុជារយៈពេល២ឆ្នាំផងដែរ។



## លោក ប៉ាន សុខន
### ប្រធាននាយកដ្ឋានព័ត៌មានវិទ្យា



លោក ប៉ាន សុខន មានបទពិសោធន៍ការងាររយៈពេលជាង ១៦ឆ្នាំ លើការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធបណ្តាញព័ត៌មានវិទ្យា ក្នុងនោះគឺ១១ឆ្នាំបានបំរើការនៅធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

ទំនួលខុសត្រូវការងារសំខាន់ៗរបស់លោក ប៉ាន សុខន គឺការគ្រប់គ្រងប្រព័ន្ធធនាគារស្នូល បណ្តាញហេដ្ឋារចនាសម្ព័ន្ធ ការគ្រប់គ្រងសន្តិសុខព័ត៌មានវិទ្យា អភិបាលកិច្ចព័ត៌មានវិទ្យា ការគ្រប់គ្រងមជ្ឈមណ្ឌលទិន្នន័យ ប្រព័ន្ធគ្រប់គ្រងព័ត៌មានអឹមអាយអេស (MIS) និងច្នេកវិទ្យាព័ត៌មានឌីជីថល។

ការចាប់ផ្តើមការងារដំបូងរបស់គាត់ គឺជាអ្នកបច្ចេកទេសព័ត៌មានវិទ្យានាឆ្នាំ២០០៣នៅក្នុងក្រុមហ៊ុនឯកជនមួយ។ លុះក្រោយមក លោក ប៉ាន សុខន បានទទួលតំណែងជាមន្ត្រីព័ត៌មានវិទ្យាជាន់ខ្ពស់និងជាអ្នកគ្រប់គ្រងប្រព័ន្ធនិងបណ្តាញព័ត៌មានវិទ្យាក្នុងឆ្នាំ២០០៩នៅធនាគារពាណិជ្ជធំមួយលំដាប់ទី៥នៅកម្ពុជា។ នៅឆ្នាំ២០១៣ គាត់បានក្លាយជាប្រធានផ្នែកព័ត៌មានវិទ្យានៅក្នុងក្រុមហ៊ុនឯកជនមួយ ហើយនៅឆ្នាំ២០១៦ គាត់ជាប្រធានផ្នែកគាំទ្រប្រព័ន្ធព័ត៌មានវិទ្យា នៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំមួយលំដាប់ទី៨នៅកម្ពុជា។

លោក ប៉ាន សុខន បានទទួលបរិញ្ញាបត្រវិទ្យាសាស្ត្រកុំព្យូទ័រពីសាកលវិទ្យាល័យន័រតុនក្នុងឆ្នាំ២០០៩ និងបានបញ្ចប់ការសិក្សាអក្សរសាស្ត្រអង់គ្លេស ពីមជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សអាស៊ីនៅកម្ពុជានៅឆ្នាំ២០១០។ នៅឆ្នាំបន្តបន្ទាប់ លោក ប៉ាន សុខន បានបញ្ចប់ថ្នាក់អនុបណ្ឌិតព័ត៌មានវិទ្យា ពីសាកលវិទ្យាល័យន័រតុន នាឆ្នាំ២០១៣។

លោក ប៉ាន សុខន ក៏បានចូលរួមវគ្គបណ្តុះបណ្តាលដូចជា ការគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យា ការគ្រប់គ្រងព័ត៌មានវិទ្យា បណ្ណាល័យហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ITIL) ប្រព័ន្ធរដ្ឋបាលម៉ាស៊ីនមេ វិស្វករ (CISCO) ផ្នែកប្រព័ន្ធ បណ្តាញការគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មាន និងភាពជាអ្នកដឹកនាំ។ លោកបានចូលរួមវគ្គបណ្តុះបណ្តាល និងជាសមាជិកក្លឹបក្រុមអ្នកជំនាញព័ត៌មានវិទ្យាតាំងពីឆ្នាំ២០១៦ រហូតមកដល់បច្ចុប្បន្ន។

លោក ប៉ាន សុខន បានចូលបំរើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ក្នុងមុខតំណែងជាប្រធាននាយកដ្ឋានព័ត៌មានវិទ្យា នៅក្នុងខែកញ្ញា ឆ្នាំ២០១៩ ។

## លោក សេង ផានិត

### ប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម



លោក សេង ផានិត បានចូលបំរើការនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក នាខែកញ្ញា ឆ្នាំ២០១៩។ លោកត្រូវបានធនាគារជាតិ នៃ កម្ពុជា ទទួលស្គាល់ថាជាបេក្ខជនមានសមត្ថភាពបំពេញតួនាទីជា ប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យនិងប្រតិបត្តិតាមរបស់គ្រឹះស្ថាន។

លោក សេង ផានិត មានបទពិសោធន៍ផ្នែកគ្រប់គ្រងហានិភ័យធនាគារនិងហិរញ្ញវត្ថុ និងការអនុវត្តច្បាប់ប្រតិបត្តិតាមបានជាង១១ឆ្នាំមកហើយ ដែលរាប់ទាំងរយៈពេល៣ឆ្នាំជាមន្ត្រីឥណទាន នៅក្នុងធនាគារពាណិជ្ជធំលំដាប់ទី២ នៅប្រទេសកម្ពុជា។

ចាប់ផ្តើមការងារពីមន្ត្រីឥណទាន លោក សេង ផានិត បានអភិវឌ្ឍជំនាញជាបន្តបន្ទាប់ ហើយបានក្លាយជាប្រធានក្រុមគ្រប់គ្រងហានិភ័យឥណទាននិងសាច់ប្រាក់នៅឆ្នាំ ២០១១។ បន្ទាប់មកលោកបានធ្វើជាប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យនិងប្រតិបត្តិតាម នៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំលំដាប់ទី៣នៅកម្ពុជាក្នុងឆ្នាំ២០១៨ ។

លោក សេង ផានិត បានបញ្ចប់បរិញ្ញាបត្រហិរញ្ញវត្ថុនិងធនាគារពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចនៅខែវិច្ឆិកា ឆ្នាំ២០០៧ ។ នៅឆ្នាំ២០១៩ លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនទាក់ទងនឹងហានិភ័យធនាគារ ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យនិងប្រតិបត្តិតាមដែលមានលិខិតបញ្ជាក់ដោយស្ថាប័ន IBF ។

លើសពីនេះទៅទៀត លោកសេង ផានិត បានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាជាច្រើនដូចជា គោលនយោបាយស្តីពីការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាមលើ AML / AMF, CFT, IFRS9 (PWC) នៅកម្ពុជា និងការគ្រប់គ្រងហានិភ័យ និងការថ្លែងបន្ទំពីធនាគារ KRUNGSRI ប្រទេសថៃ។



## លោក យក់ សារឿន
### ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង



លោក យក់ សារឿន បានចូលបំរើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ក្នុងមុខតំណែងជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង នាខែកញ្ញា ឆ្នាំ២០១៩។

លោកត្រូវបានធនាគារជាតិ នៃ កម្ពុជា ទទួលស្គាល់ជាបេក្ខជនមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីបំពេញតួនាទីជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់គ្រឹះស្ថាន។

លោក យក់ សារឿន មានបទពិសោធន៍ការងាររយៈពេលជាង១២ឆ្នាំ ទាក់ទងនឹងផ្នែកសេវាកម្មហិរញ្ញវត្ថុ ធនាគារ និងមីក្រូហិរញ្ញវត្ថុ ដោយលោកបានចាប់ផ្តើមការងារដំបូងជាមន្ត្រីឥណទាន នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ រយៈពេលជិត៣ឆ្នាំ។ បន្ទាប់មក លោកបានចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត ក្នុងឆ្នាំ២០១០ ជាគណនេយ្យករ។ លោកក៏ត្រូវបានដំឡើងឋានៈជា ប្រធានផ្នែកសវនកម្មហិរញ្ញវត្ថុនៅឆ្នាំ២០១៣នៅក្នុងគ្រឹះស្ថានដដែល។

លោក សារឿន ធ្លាប់ជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងរយៈពេលជាង២ឆ្នាំ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល និងជាជំនួយការនាយកគណនេយ្យនិងហិរញ្ញវត្ថុនៅធនាគារភ្នំពេញពាណិជ្ជ។

លោក សារឿន បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងហិរញ្ញវត្ថុពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅក្នុងឆ្នាំ២០១២។ លោកក៏បានបញ្ចប់ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ចជំនាញធនាគារ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅក្នុងឆ្នាំ២០០៦។

លើសពីនេះ លោកបានចូលរួមសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលដូចជា៖ គណនេយ្យ ពន្ធដារ សវនកម្មលើបច្ចេកវិទ្យាព័ត៌មាន សវនកម្មពន្ធដារ និងការរៀបចំផែនការពន្ធដារ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ប្រព័ន្ធត្រួតពិនិត្យហានិភ័យ និងការកេងបន្លំ គន្លឹះនៃការគ្រប់គ្រងហានិភ័យ និងវគ្គបណ្តុះបណ្តាលផ្សេងៗមួយចំនួនទៀត។

## លោក អ៊ាម ចណ្ណា
### អនុប្រធាននាយកដ្ឋានប្រតិបត្តិការឥណទាន

លោក អ៊ាម ចណ្ណា ធ្លាប់ជាប្រធានសាខានៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លី ហួរ ភីអិលស៊ី ក្នុងឆ្នាំ២០១៨។ លោកត្រូវបានផ្លាស់ប្តូរទៅនាយកដ្ឋានអភិវឌ្ឍអាជីវកម្ម នៅគ្រឹះស្ថានដដែលនៅឆ្នាំ២០១៩ដើម្បីចូលរួមរៀបចំផែនការយុទ្ធសាស្ត្រ និងជំរុញសកម្មភាពរបស់គ្រឹះស្ថាន ឱ្យសម្រេចគោលដៅប្រកបដោយប្រសិទ្ធភាព និងមានគុណភាពដល់ផលប័ត្រកម្ចីរបស់គ្រឹះស្ថាន។



លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកអភិវឌ្ឍន៍ជនបទនៅក្នុងឆ្នាំ២០១០ និងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុ និងធនាគារ នៅក្នុងឆ្នាំ២០១៣ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង នៃ កម្ពុជា។

លើសពីនេះ លោកក៏បានចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលជាច្រើនដែលទាក់ទងនឹងជំនាញ ប្រតិបត្តិការទីផ្សារ ការគ្រប់គ្រងឥណទាន ការគ្រប់គ្រងសាខា និងការគ្រប់គ្រងប្រាក់កម្ចី ដែលធ្វើឡើងដោយផ្ទៃក្នុងគ្រឹះស្ថាន និងវិទ្យាស្ថានដៃគូនៅប្រទេសកម្ពុជា។

លោក អ៊ាម ចណ្ណា បានចូលបំរើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ជាអនុប្រធាននាយកដ្ឋានប្រតិបត្តិការឥណទាន ក្នុងខែធ្នូ ឆ្នាំ២០១៩។

លោក អ៊ាម ចណ្ណា មានបទពិសោធន៍ការងាររយៈពេលជាង៨ឆ្នាំទាក់ទងនឹងវិស័យហិរញ្ញវត្ថុនិងប្រតិបត្តិការឥណទានធនាគារ និងមីក្រូហិរញ្ញវត្ថុ។



## អនុស្សរណៈយោគយល់គ្នារវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក និង ក្រុមហ៊ុន ហ្វាយ ស្តារ រេសុីដេន អេសអ ឯ.ក

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក បានចុះអនុស្សរណៈនៃកិច្ចព្រមព្រៀងយោគយល់គ្នា (MOU) ជាមួយក្រុមហ៊ុន ហ្វាយ ស្តារ រេសុីដេន អេសអ ឯ.ក សម្រាប់គម្រោងឥណទានគេហដ្ឋានដល់អតិថិជនដែលទិញផ្ទះល្វែង ផ្ទះម៉ាត ផ្ទះអាជីវកម្ម និងវីឡារបស់បុរី ហ្វាយ ស្តារ ទាំងគម្រោងទី១ និងទី២ ដែលស្ថិតនៅក្នុងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ព្រះរាជាណាចក្រកម្ពុជា។

គោលបំណងនៃអនុស្សរណៈយោគយល់គ្នានេះគឺ ដើម្បីលើកកម្ពស់ភាពជាម្ចាស់គេហដ្ឋានរបស់អតិថិជន រួមទាំងគាំទ្រដល់អាជីវកម្មសំណង់ ហើយក៏ដើម្បីពង្រីកផលប័ត្រប្រាក់កម្ចីគេហដ្ឋាន របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ដល់អ្នកប្រើប្រាស់ផ្ទាល់ជាមួយនឹងសេវាកម្ម ដែលអាចទុកចិត្តបាន មានគុណភាពខ្ពស់ និងតម្លៃប្រកួតប្រជែងនៅក្នុងទីផ្សារកម្ពុជា។



## អនុស្សារណៈយោគយល់គ្នារវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក និង ធនាគារឯកទេសវីង (ខេមបូឌា) លីមីធីត

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក និង ធនាគារឯកទេសវីង (ខេមបូឌា) លីមីធីត បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងលេខ៖ ១១៩១០១-០៨ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២០ សម្រាប់កិច្ចព្រមព្រៀងកម្រិតសេវាកម្មជាដៃគូដ៏ទូលំទូលាយ ឬ ហៅកាត់ថា PSLA។

គោលបំណងនៃកិច្ចព្រមព្រៀងកម្រិតសេវាកម្ម ជាដៃគូដ៏ទូលំទូលាយនេះគឺ ដើម្បីបង្ហាញពីទំនាក់ទំនង និង ការរំពឹងទុកដើម្បីផ្តល់ជូននូវគុណភាព សុវត្ថិភាព ក៏ដូចជាសេវាកម្មឌីជីថល ដល់អតិថិជនក្នុងការសងប្រាក់កម្ចី និងដំណោះស្រាយហិរញ្ញវត្ថុផ្សេងៗទៀតជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក តាមរយៈសេវាកម្មវីង។

ថ្ងៃនេះអតិថិជនអាចធ្វើការទូទាត់បង់ប្រាក់កម្ចី ដោយផ្ទាល់ទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក តាមរយៈគណនីវីងពីកម្មវិធីស្មាតហ្វូនផ្ទាល់ខ្លួន ឬស្វែងរកភ្នាក់ងារវីងដែលនៅជិតបំផុត សម្រាប់ធ្វើប្រតិបត្តិការទូទាត់ប្រាក់ ដើម្បីកាត់បន្ថយការចំណាយពេល ទៅកាន់បញ្ជរបង់ប្រាក់របស់គ្រឹះស្ថាន(នៅការិយាល័យជាដើម) ។






គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក បានបើកកម្មវិធីចាប់ឆ្នោតផ្សងសំណាងយករង្វាន់អនុស្សាវរីយ៍ដំបូង ក្នុងឱកាសបុណ្យចូលឆ្នាំចិនក្នុងឆ្នាំ២០២០ ដែលមានរយៈពេល៣ខែក្នុងការផ្តល់ជូនដល់អតិថិជនដែលបានទិញផ្ទះបុរី ហ្វាយ ស្តារ។ ក្រៅអំពីភាពជាម្ចាស់ផ្ទះ អតិថិជនក៏មានឱកាសទទួលបានកាដូអនុស្សាវរីយ៍ដូចជា៖ បន្តោងខ្សែកមាស ទូរទស្សន៍ឆ្លាតវៃ ទូទឹកកក ទូរស័ព្ទដៃ និងម៉ាស៊ីនត្រជាក់។ល។

លោក បូរ ឧត្តមវិជ្ជា បានចាប់ផ្តើមធ្វើជំនួញផ្នែកសេវាកម្មវេរប្រាក់រឹង និងម៉ាតចាប់តាំងពីដើមឆ្នាំ២០១៩។ ឧត្តមវិជ្ជាត្រូវបានផ្តល់ឥណទានគេហដ្ឋានសម្រាប់ទិញផ្ទះនៅបុរី ហ្វាយ ស្តារ គម្រោងទី១ ល្វែងលេខអេស-០៥៦, អេវី១ ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក។





កញ្ញា សេង ស្រីនិត បានចាប់ផ្តើមធ្វើអាជីវកម្មផ្នែកសេវាកម្មម៉ាស្សាដោយជនពិការ នៅដើមឆ្នាំ២០១៧។ ស្រីនិតត្រូវបានផ្តល់ឥណទានគេហដ្ឋានសម្រាប់ទិញផ្ទះនៅបុរី ហ្វាយ ស្តារ គម្រោងទី២ ល្វែងលេខអិលវី-២៧៦, អិលវី៥ ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ។

លោកស្រី ថុន កាណ្ណារ៉ា បានចាប់ផ្តើមធ្វើជំនួញផ្នែកផ្គត់ផ្គង់សម្ភារៈសំអាងនិងកែសម្ផស្សនាដើមឆ្នាំ២០១៩។ កាណ្ណារ៉ា ត្រូវបានផ្តល់ឥណទានគេហដ្ឋានសម្រាប់ទិញផ្ទះនៅបុរី ហ្វាយ ស្តារ គម្រោងទី២ ល្វែងលេខអិលវី-១៦១, អិលវី៣ ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក។



# កម្មវិធីបណ្តុះបណ្តាល និងការអភិវឌ្ឍបុគ្គលិកប្រចាំឆ្នាំ២០២០



កម្មវិធីបណ្តុះបណ្តាល និងការអភិវឌ្ឍបុគ្គលិក ពិតជាមានសារៈសំខាន់សម្រាប់ការធានានូវប្រសិទ្ធភាពការងាររបស់និយោជិតនៅក្នុងគ្រឹះស្ថាន។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក បានពង្រីកចំណេះដឹងដល់បុគ្គលិកដែលជាទ្រព្យវិនិយោគ ដ៏មានតម្លៃបំផុត សម្រាប់មូលដ្ឋានធនធានមនុស្ស ដែលមនុស្សជាច្រើនជឿជាក់លើការវិនិយោគនេះ។

កម្មវិធីនេះផងដែរ ក៏ផ្តោតសំខាន់ទៅលើការបង្កើនជំនាញ សមត្ថភាព គុណភាព និងបញ្ញារបស់និយោជិតដើម្បីភាពរីកចម្រើនរបស់គ្រឹះស្ថាន។

## នាយកដ្ឋានរដ្ឋបាលនិងធនធានមនុស្ស៖

ផ្នែកដំបូងនៃវគ្គបណ្តុះបណ្តាលធនធានមនុស្ស ត្រូវបានចំណាយពេល ២០ម៉ោង សម្រាប់ការបញ្ចប់ជាមួយបុគ្គលិក៩នាក់។ វគ្គបណ្តុះបណ្តាលនេះត្រូវបានបង្រៀនដោយលោក ជួន ពិសិដ្ឋ ប្រធាននាយកដ្ឋានរដ្ឋបាលនិងធនធានមនុស្ស។ មុខវិជ្ជានៃវគ្គសិក្សាមានដូចជា៖ គោលនយោបាយនិងនីតិវិធីធនធានមនុស្ស ក្រមសីលធម៌បុគ្គលិក បទបញ្ជាផ្ទៃក្នុង ទំនាស់ផលប្រយោជន៍ ការមិនរើសអើង និងនីតិវិធីប្រាក់បុរេប្បទាន។ សិក្ខាកាមទាំងអស់ត្រូវបានបញ្ចប់ដោយជោគជ័យ និងទទួលបានវិញ្ញាបនបត្របញ្ជាក់វគ្គសិក្សាផងដែរ។





## នាយកដ្ឋានគ្រប់គ្រងហានិភ័យនិងប្រតិបត្តិតាម៖

នាយកដ្ឋានបានអនុវត្តការងារវគ្គបណ្តុះបណ្តាល ដោយបានចំណាយពេល ២៨ម៉ោងសម្រាប់ការបញ្ចប់ និងមានបុគ្គលិកចូលរួមចំនួន១៨នាក់។ វគ្គបណ្តុះបណ្តាលនេះត្រូវបានបង្រៀនដោយលោក សេង ផានិត ប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យនិងប្រតិបត្តិតាម។ មុខវិជ្ជានៃវគ្គសិក្សានេះមានដូចជា៖ ការគ្រប់គ្រងហានិភ័យទូទៅ ក្របខ័ណ្ឌនៃការអនុវត្តច្បាប់ គោលនយោបាយនិងនីតិវិធី AMLនិងCFT, នីតិវិធីវាយតម្លៃ KYC, របាយការណ៍ CTRនិងSTR។ សិក្ខាកាមទាំងអស់បានបញ្ចប់វគ្គបណ្តុះបណ្តាលដោយជោគជ័យនិងទទួលបានវិញ្ញាបនបត្របញ្ជាក់វគ្គសិក្សាផងដែរ។




## នាយកដ្ឋានសវនកម្មផ្ទៃក្នុង ៖

នាយកដ្ឋានបានរៀបចំវគ្គបណ្តុះបណ្តាល រយៈពេល ១៦ម៉ោង សម្រាប់ការបញ្ចប់ជាមួយសិក្ខាកាមចំនួន១៣នាក់។ វគ្គបណ្តុះបណ្តាលនេះត្រូវបានបង្រៀនដោយលោក យក់ សារឿន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង។ មុខវិជ្ជាក្នុងវគ្គបណ្តុះបណ្តាលនេះមានដូចជា៖ គោលនយោបាយសវនកម្មផ្ទៃក្នុង ការយល់ដឹងពីការបន្លំនិងការការពារការបន្លំ។ សិក្ខាកាមទាំងអស់ បានបញ្ចប់វគ្គដោយជោគជ័យ និងទទួលបានវិញ្ញាបនបត្របញ្ជាក់វគ្គសិក្សាផងដែរ។

## នាយកដ្ឋានព័ត៌មានវិទ្យា (IT) ៖

វគ្គបណ្តុះបណ្តាលទី១នៃមុខវិជ្ជាព័ត៌មានវិទ្យានេះគឺផ្តោតទៅលើមូលដ្ឋានគ្រឹះនៃបច្ចេកវិទ្យាព័ត៌មាន និងការថែទាំកុំព្យូទ័របឋមពីអ្នកប្រើប្រាស់។ វគ្គនេះត្រូវបានចំណាយពេល៨ម៉ោង សម្រាប់ការបញ្ចប់ជាមួយសិក្ខាកាមចំនួន១០នាក់។ វគ្គបណ្តុះបណ្តាលនេះដែរ ត្រូវបានបង្រៀនដោយលោក ប៉ាន សុខន ប្រធាននាយកដ្ឋានព័ត៌មានវិទ្យា។ មុខវិជ្ជានៃវគ្គបណ្តុះបណ្តាលរួមមាន៖ ការណែនាំអំពីឧបករណ៍ ICT វិធីប្រើឧបករណ៍អេឡិចត្រូនិកតាមវិធីត្រឹមត្រូវ ការណែនាំអំពីសុវត្ថិភាពកុំព្យូទ័រ តាមអ៊ីនធឺណេត និងវិធីការពារការវាយប្រហាររបស់មេរោគតាមអ៊ីនធឺណេត។ សិក្ខាកាមទាំងអស់ត្រូវបានបញ្ចប់ដោយជោគជ័យនិងទទួលបានវិញ្ញាបនបត្របញ្ជាក់វគ្គសិក្សាផងដែរ។





## នាយកដ្ឋានហិរញ្ញវត្ថុ ៖

វគ្គបណ្តុះបណ្តាលទី១ នៃមុខវិជ្ជាគណនេយ្យ និងហិរញ្ញវត្ថុ បានចំណាយពេល៨ម៉ោង សម្រាប់ការបញ្ចប់ដោយមានសិក្ខាកាមចូលរួមចំនួន៣នាក់។ វគ្គបណ្តុះបណ្តាលនេះត្រូវបានបង្រៀនដោយអ្នកស្រី ប៊ួន ច័ន្ទសុភា ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ។ មុខវិជ្ជានៃវគ្គបណ្តុះបណ្តាលនេះមានដូចជា៖ គោលនយោបាយហិរញ្ញវត្ថុនិងគណនេយ្យ នីតិវិធីគ្រប់គ្រងសាច់ប្រាក់ និងនីតិវិធីទូទាត់តាមសេវាកម្មវីង។ សិក្ខាកាមបានបញ្ចប់វគ្គសិក្សាដោយជោគជ័យនិងទទួលបានវិញ្ញាបនបត្របញ្ជាក់មុខវិជ្ជាសិក្សាផងដែរ។

# រូបថតអនុស្សាវរីយ៍និងសកម្មភាពផ្សេងៗនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ក្នុងឆ្នាំ២០២០



រូបថតជួបជុំគ្នានៃភាគទុនិក ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងបុគ្គលិកត្រូវបានថតបន្ទាប់ពីកិច្ចប្រជុំនៃក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងបានបញ្ចប់។ កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ត្រូវបានរៀបចំឡើងរៀងរាល់ឆមាសនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ការិយាល័យកណ្តាល។ គោលបំណងនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនេះគឺ ដើម្បីអនុញ្ញាតឱ្យគណៈគ្រប់គ្រងបង្ហាញអំពីបញ្ហាណាមួយដែលគ្រឹះស្ថានកំពុងប្រឈម និងពិនិត្យមើលការអនុវត្តគោលនយោបាយរបស់គ្រឹះស្ថាន ព្រមទាំងពិភាក្សាអំពីគោលនយោបាយថ្មីដែលត្រូវអនុម័ត។ លទ្ធផលក្នុងឆ្នាំ២០២០ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលបានអនុម័តលើផែនការអាជីវកម្មរបស់គ្រឹះស្ថាន ការធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងការគៀងគរមូលនិធិដើម្បីពង្រីកផលប័ត្រឥណទានរបស់គ្រឹះស្ថាន។

ក្នុងឆ្នាំ២០២០ ជំងឺរាតត្បាតកូវីដ១៩បានបង្កផលប៉ះពាល់យ៉ាងខ្លាំងទាំងផ្នែកសុខភាពសាធារណៈ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដល់មនុស្សជាតិទូទាំងពិភពលោករួមទាំងកម្ពុជាផងដែរ។ ទោះបីស្ថិតក្នុងស្ថានភាពបែបនេះក្តី ថ្នាក់ដឹកនាំរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក បាននៅបន្តអនុវត្តកិច្ចការសំខាន់ៗជាមួយដៃគូអាជីវកម្ម និងអតិថិជន ដោយមិនពន្យាពេលឡើយ។ ថ្នាក់គ្រប់គ្រងក៏បានប្រតិបត្តិតាមយន្តការសំខាន់ៗមួយចំនួន ដែលបានណែនាំដោយអាជ្ញាធរដូចជា៖ ការត្រួតពិនិត្យសីតុណ្ហភាពបុគ្គលនៅតាមការិយាល័យ ការរក្សាគម្លាតចម្ងាយសង្គមពី១,៥ម៉ែត្រឡើងទៅនិងការរក្សាអនាម័យឱ្យបានខ្ជាប់ខ្ជួនដើម្បីការពារការឆ្លងវីរុសកូវីដ១៩។





គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក បានបន្តផ្តល់ឥណទានដល់អតិថិជនជាពិសេសក្នុងវិស័យហិរញ្ញប្បទានគេហដ្ឋាន ទោះបីកំពុងស្ថិតក្នុងកាលៈទេសៈ វីរុសកូវីដ១៩រាតត្បាតយ៉ាងណាក្តី។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក បានអនុវត្តតាមប្រកាសរបស់ធនាគារជាតិ នៃ កម្ពុជា ស្តីអំពីការណែនាំឱ្យស្ថាប័នហិរញ្ញវត្ថុនិងធនាគារទាំងអស់ រៀបចំឥណទានឡើងវិញដល់អតិថិជនដែលមានវិបត្តិប្រាក់ចំណូល ដែលរងផលប៉ះពាល់ដោយសារការរីករាលដាលនៃវីរុសកូវីដ១៩និងរងគ្រោះដោយទឹកជំនន់នៅទូទាំងប្រទេសកម្ពុជានាឆ្នាំ២០២០នេះ បើមានការស្នើសុំពីអតិថិជនគឺក្នុងគោលបំណងជួយពួកគេឱ្យរក្សាបាននូវស្ថិរភាពហិរញ្ញវត្ថុ ក្នុងគ្រាដ៏លំបាកនេះ។



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
NATION RELIGION KING

ក្រសួងពាណិជ្ជកម្ម
MINISTRY OF COMMERCE

វិញ្ញាបនបត្រ
បញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
CERTIFICATE OF INCORPORATION

លេខ(No) MOC-54976363 ពណ.ចបព

| | | |
|---|---|---|
| នាមករណ៍ / NAME | : | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក / G B MICROFINANCE INSTITUTION PLC. |
| REGISTRATION NUMBER | : | 00043909 |
| INCORPORATION DATE | : | 21 មិថុនា 2019 / 21 June 2019 |
| IS INCORPORATED AS | : | Public Limited Company |

ភ្នំពេញ, 21 មិថុនា 2019
PHNOM PENH, 21 JUNE 2019
F. MINISTER OF COMMERCE
Director General
KAO KOSAL

UNDER THE REGULATIONS OF COMMERCIAL RULES AND REGISTER LAW, COMMERCIAL ENTERPRISES LAW, CIVIL CODE AND PENAL CODE OF THE KINGDOM OF CAMBODIA

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក បានទទួលវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះ ក្នុងបញ្ជីពាណិជ្ជកម្ម លេខ ០០០៤៣៩០៩, ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ពីក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក បានទទួលអាជ្ញាបណ្ណប្រកបអាជីវកម្មគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពីធនាគារជាតិ នៃកម្ពុជា លេខ ម.ហ ៩២ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩។



ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

NATIONAL BANK OF CAMBODIA

LICENSE TO CONDUCT MICROFINANCE BUSINESS

N° : M.F 92

THE NATIONAL BANK OF CAMBODIA

allows G B PLC. to conduct business as microfinance institution with head office at N° J37, Phleuv Lum, Sangkat Tonle Basak, Khan Chamkar Mon, Phnom Penh.

Microfinance Institution G B PLC. shall abide by the Law on Banking and Financial Institutions and Prakas, regulations, circulars, and conditions prescribed by the National Bank of Cambodia.

Phnom Penh, October 22, 2019
Governor

- This license is valid until October 22, 2022
- This license shall be displayed in public at all times



សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា
Cambodia Microfinance Association

Membership N°: 122 /20CMA
Joining Date: 30/01/2020

សូមបញ្ជាក់ថា
This is to certify that

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក
GB MICROFINANCE INSTITUTION PLC.

ជាសមាជិកធម្មតារបស់សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា
is Ordinary Member of Cambodia Microfinance Association

Phnom Penh, 30 January.... 2020

Mr. Kea Borann
Chairman

Mr. Phal Vandy
Executive Director

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ត្រូវបានទទួលស្គាល់ជាសមាជិកនៃសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា(CMA) ដែលមានវិញ្ញាបនបត្រសមាជិក លេខ ១២២/២០ ស៊ីអឹមអេ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០។

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក**

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៨)

លេខចុះបញ្ជីក្រុមហ៊ុន: 00043909

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសូមបង្ហាញរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល រួមជាមួយរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ក្រុមហ៊ុន នាការិយបរិច្ឆេទ និង ចុងការិយបរិច្ឆេទបញ្ចប់ត្រឹម ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០។

### ក្រុមប្រឹក្សាភិបាល

សមាសភាពនៃក្រុមប្រឹក្សាភិបាលដែលបានបម្រើការងារក្នុងកំឡុងឆ្នាំហិរញ្ញវត្ថុ និងរហូតដល់ចុងកាលបរិច្ឆេទនៃរបាយការណ៍នេះមានដូចខាងក្រោម:

| | |
|---|---|
| លោក តាំង គួងហាវ | ប្រធានក្រុមប្រឹក្សាភិបាល |
| លោកស្រី ស៊ី, ជា-ជា | អភិបាល |
| លោក តាំង កៅគៀត | អភិបាល |

### ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលចំពោះរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលជាអ្នកទទួលខុសត្រូវដើម្បីធានាថារបាយការណ៍ហិរញ្ញវត្ថុផ្តល់នូវទិដ្ឋភាពពិត និង ត្រឹមត្រូវអំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាចុងការិយបរិច្ឆេទថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ និងលទ្ធផលនៃប្រតិបត្តិការហើយ និង លំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០។
ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនតម្រូវឲ្យ៖

ក) អនុម័តគោលនយោបាយគណនេយ្យសមស្របទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិកម្ពុជាសម្រាប់សហគ្រាសធុនតូចនិង មធ្យម ("CIFRS សម្រាប់សហគ្រាសធុនតូចនិងមធ្យម") ដែលតម្រូវឲ្យមានការវិនិច្ឆ័យ និង ការប៉ាន់ស្មានដោយសមហេតុផល ហើយបន្ទាប់មកត្រូវអនុវត្តគោលនយោបាយ ទាំងនោះជាអចិន្ត្រៃយ៍។

ខ) អនុវត្តតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម ឬ ប្រសិនបើមានគម្លាតពីស្តង់ដារទាំងនេះដែលជាប្រយោជន៍ដល់ការបង្ហាញនូវភាពពិត និងត្រឹមត្រូវរបស់របាយការណ៍ហិរញ្ញវត្ថុ គម្លាតទាំងនោះត្រូវបានបង្ហាញ ពន្យល់ឲ្យបានច្បាស់លាស់ និងកំណត់ចំនួនជាទឹកប្រាក់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

គ) រក្សាទុកនូវបញ្ជីការគណនេយ្យឲ្យបានត្រឹមត្រូវ និង ធានាការគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធិភាព។

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៥)

លេខចុះបញ្ជីក្រុមហ៊ុន: 00043909

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

### ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលចំពោះរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុផ្អែកលើមូលដ្ឋាននិរន្តភាពនៃ ដំណើរការអាជីវកម្មលើកលែងតែក្នុងករណីដែលមានការសន្មត់ថាក្រុមហ៊ុននឹងមិនបន្តប្រតិបត្តិការនៅអនាគតដ៏ខ្លី និង

ង) បង្កើតគោលនយោបាយទូទៅសម្រាប់ក្រុមហ៊ុនអនុម័តរាល់ការសម្រេចចិត្តនិងសកម្មភាពទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនដែលមានផលប៉ះពាល់ជាសារវន្តលើប្រតិបត្តិការអាជីវកម្ម និងលទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ហើយត្រូវធានាថាគោលនយោបាយ និងការសម្រេចចិត្តទាំងអស់នោះត្រូវបានឆ្លុះបញ្ចាំងយ៉ាងពិតប្រាកដក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនបានធានាអះអាងថាក្រុមហ៊ុនបានអនុវត្តន៍ទៅតាម លក្ខខណ្ឌចាំបាច់នានាដូច ដែលបានបញ្ជាក់ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

តាមគំនិតរបស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានបង្កើតឡើងស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ដើម្បីផ្តល់នូវទស្សនៈពិត នឹង ត្រឹមត្រូវ ពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០ និងលទ្ធផលនៃប្រតិបត្តិការនិងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ចុងការិយបរិច្ឆេទ ។

### ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលបានយកចិត្តទុកដាក់ទៅលើបញ្ហាដូចខាងក្រោម៖

ក) រាល់សារវន្តទាំងអស់ផ្ទេរទៅ ឬ ពីទុនបំរុង ឬ សំវិធានធនក្នុងឆ្នាំហិរញ្ញវត្ថុត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ខ) សំវិធានធនគ្រប់គ្រាន់សម្រាប់ការខាតបង់លើគណនីដែលត្រូវទារ និងទ្រព្យសកម្មបច្ចុប្បន្ន និងទ្រព្យអកម្មត្រូវបានអនុវត្តបើសិនបើចាំបាច់។

គ) បំណុលអសារបង់ត្រូវបានលុបចោល ប្រសិនបើមាន។

ឃ) វិធីសាស្ត្រនៃការវាយតម្លៃទ្រព្យសកម្ម ឬបំណុលដែលមានស្រាប់គឺមិនខុសឆ្គងឬមិនសមរម្យ។

ង) មិនមានកាលៈទេសៈណាមួយដែលអាចដឹងពីចំនួនទឹកប្រាក់ណាក៏ដោយដែលបានបញ្ជាក់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលនាំឱ្យមានការភាន់ច្រឡំ។

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)

លេខចុះបញ្ជីក្រុមហ៊ុន: 00043909

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

### ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

ច) មិនមានគម្លាតរវាងរបាយការណ៍ហិរញ្ញវត្ថុចុងការិយបរិច្ឆេទ ធៀបនឹង របាយការណ៍ក្នុងកាលបរិច្ឆេទនេះ ដូចជា ធាតុណាមួយ ប្រតិបត្តិការ ឬ ចំណុចសំខាន់ណាមួយដែលមានលក្ខណ:ខុសប្រក្រតី ទៅតាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល ដែលនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនសម្រាប់ក្នុងកំឡុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុដែលរបាយការណ៍វាយការណ៍នេះត្រូវបានធ្វើ ឡើង។

ឆ) លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងកំឡុងពេល នៃឆ្នាំហិរញ្ញវត្ថុនេះមិនត្រូវបានទទួលរងផលប៉ះពាល់ដោយធាតុណាមួយ ប្រតិបត្តិការ ឬ ចំណុចសំខាន់ណាមួយដែលមានលក្ខណ:ខុសប្រក្រតី។

ជ) គ្មានយថាហេតុ រឺបំណុលផ្សេងទៀតរបស់ក្រុមហ៊ុនបានក្លាយទៅជាប្រតិបត្តិ ឬអាចនឹងត្រូវបានអនុវត្តន៍ក្នុងកំឡុងពេល 12 ខែ បន្ទាប់ពីការបញ្ចប់ឆ្នាំហិរញ្ញវត្ថុដែលក្នុងមតិយោបល់របស់ក្រុមប្រឹក្សាភិបាល នឹងមាន ឬអាចប៉ះពាល់ដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដែលប្រតិបត្តិការនោះដល់កាលកំណត់។

### ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ដែលបានភ្ជាប់ជាមួយរបាយការណ៍នេះថាពិតជាបង្ហាញពីទិដ្ឋភាពពិត និង ត្រឹមត្រូវពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាចុងការិយបរិច្ឆេទថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ ហើយនិងលទ្ធផលនៃប្រតិបត្តិការ និង លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ទៅតាមស្តង់ដារហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់ សហគ្រាសធុនតូច និង មធ្យម។

លោក តាំង គួងហាវ

ប្រធានក្រុមប្រឹក្សាភិបាល

Crowe

Crowe (KH) Co., Ltd
*Chartered Accountants*
Member Crowe International

Unit 4B, K1 Building (#148), Mao Tse Tung Blvd, Sangkat Toul Tumpung II, Khan Chamkar Morn, Phnom Penh
Kingdom of Cambodia
Main +855 23 216 717
www.crowe.com.kh
info@crowe.com.kh

## របាយការណ៍របស់សវនករឯករាជ្យសម្រាប់សមាជិកនៃ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)
(លេខចុះបញ្ជីក្រុមហ៊ុន: 00043909)

### ការរាយការណ៍លើរបាយការណ៍ហិរញ្ញវត្ថុ

### ទស្សនៈរបស់សវនករ

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក ហៅថា ("ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ និង របាយការណ៍លទ្ធផលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន និង របាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ ហើយនិងគោលការណ៍គណនេយ្យសំខាន់ៗព្រមទាំងកំណត់សម្គាល់ផ្សេងៗ ដែលមាន ចាប់ពីទំព័រទី០៩ ដល់ ទំព័រទី ៥៤។

តាមទស្សនៈរបស់យើងខ្ញុំរបាយការណ៍ហិរញ្ញវត្ថុនេះបង្ហាញនូវទិដ្ឋភាពពិតប្រាកដ និង ត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការហិរញ្ញវត្ថុហើយនិងលំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទបញ្ចប់ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និង មធ្យម។

### មូលដ្ឋាននៃទស្សនៈរបស់សវនករ

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិ។ ការទទួលខុសត្រូវរបស់ពួកយើងគឺស្ថិតនៅក្រោមស្តង់ដារដែលបានចែង និងរៀបរាប់នៅក្នុងផ្នែកទំនួលខុសត្រូវរបស់សវនករទៅលើរបាយការណ៍ហិរញ្ញវត្ថុនៃរបាយការណ៍សវនកម្មរបស់ពួកយើង។ យើងជឿជាក់ថាភស្តុតាងសវនកម្ម ដែលពួកយើងប្រមូលបានគឺគ្រប់គ្រាន់ និងសមហេតុផល ដើម្បីជាមូលដ្ឋានក្នុងការផ្តល់មតិយោបល់របស់យើងខ្ញុំ។

### ទំនួលខុសត្រូវរបស់សវនករឯករាជ្យ និងក្រមសីលធម៌

យើងខ្ញុំជាសវនករឯករាជ្យ ដែលតម្រូវឲ្យអនុលោមតាមក្រមសីលធម៌ ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជា។ ហើយយើងខ្ញុំបានបំពេញនូវរាល់ទំនួលខុសត្រូវនានាដែលតម្រូវដោយក្រមសីលធម៌នេះផងដែរ។

**របាយការណ៍របស់សវនករឯករាជ្យសម្រាប់សមាជិកនៃ**
**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក**

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)
(លេខចុះបញ្ជីក្រុមហ៊ុន: 00043909)

**ព័ត៌មានបន្ថែមទៅលើរបាយការណ៍ហិរញ្ញវត្ថុ និង របាយការណ៍របស់សវនករមានដូចតទៅនេះ**

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនគឺជាអ្នកទទួលខុសត្រូវរាល់ពត៌មានដែលជាប់ពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុន។ ព័ត៌មាននោះរួមបញ្ចូលទាំងរបាយការណ៍ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនបានរួមបញ្ចូលជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរបាយការណ៍របស់សវនករឡើយ។

ការបញ្ចេញទស្សនៈរបស់ពួកយើងទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គឺមិនបានរាប់បញ្ចូលជាមួយរបាយការណ៍ក្រុមប្រឹក្សាភិបាលឡើយ ហើយពួកយើងក៏មិនបានបង្ហាញជាលិខិតអះអាងទៅលើការសរុបមតិរបស់របាយការណ៍នោះផងដែរ។

ក្នុងការភ្ជាប់គ្នារវាងការធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ចំពោះទំនួលខុសត្រូវរបស់សវនករគឺគ្រាន់តែស្វែងយល់អំពី របាយការណ៍របស់ក្រុមប្រឹក្សាភិបាល និងទទួលយករបាយការណ៍របស់ពួកគាត់ បើទោះបីជារបាយការណ៍របស់ក្រុមប្រឹក្សាភិបាលមានភាពមិនត្រឹមត្រូវទាក់ទងទៅ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនក៏ដោយ រឺក៏មានភាពមិនប្រក្រតីចំពោះវិជ្ជាជីវៈរបស់សវនករដែលបានធ្វើសវនកម្ម រឺក៏ការកើតឡើងនូវភាពខុសប្រក្រតីណាមួយផ្សេងទៀត។

យោងទៅតាមការងារដែលពួកយើងបានបំពេញ ពួកយើងបានសន្និដ្ឋានថា វានឹងមានភាពមិនត្រឹមត្រូវទាក់ទងជាមួយរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល។ ហេតុដូចនេះហើយទើបបានជាពួកយើងទាមទារនូវរបាយការណ៍ដែលពិតប្រាកដ និងត្រឹមត្រូវ។ យើងខ្ញុំគ្មានអ្វីដែលត្រូវរាយការណ៍ពីបញ្ហានេះទៀតឡើយ។

**ទំនួលខុសត្រូវរបស់អភិបាលទៅលើរបាយការណ៍ហិរញ្ញវត្ថុ**

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនជាអ្នកទទួលខុសត្រូវចំពោះការរៀបចំ និង ការបង្ហាញទិដ្ឋភាពពិតប្រាកដនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម និងការណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា។ ក្រុមប្រឹក្សាភិបាលត្រូវទទួលខុសត្រូវដូចគ្នាផងដែរចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលក្រុមប្រឹក្សាភិបាលក្រុមហ៊ុនយល់ថាមានសារៈប្រយោជន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលពុំមានកំហុសឆ្គងជាសារវ័ន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ។

Crowe

## របាយការណ៍របស់សវនករឯករាជ្យសម្រាប់សមាជិកនៃ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៨)
(លេខចុះបញ្ជីក្រុមហ៊ុន: 00043909)

### ទំនួលខុសត្រូវរបស់អភិបាលទៅលើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ត្រូវមានការទទួលខុសត្រូវពល់សកម្មភាពរបស់ក្រុមហ៊ុនដែលធានាអះអាងថា អាចមានលទ្ធភាពបន្តក្នុងរយៈពេល១២ខែខាងមុខ និងពល់បញ្ហាដែលមានជាប់ពាក់ព័ន្ធជាមួយនឹងលទ្ធភាពអាចបន្តរបស់ក្រុមហ៊ុន និងគោលបំណងដែលអាចធ្វើឲ្យមានសកម្មភាពនេះកើតឡើង ដែលតម្រូវឲ្យធ្វើការបង្ហាញទៅជាសាធារណៈដោយសារតែវាមានភាពចាំបាច់។ លើកលែងតែក្រុមប្រឹក្សាភិបាលណាមួយមានបំណងចង់ទូទាត់បំណុលរបស់ក្រុមហ៊ុនទាំងស្រុង រឺក៏អះអាងថានឹងបិទក្រុមហ៊ុន ហើយបើគ្មានសកម្មភាពណាមួយលេចឡើងនោះទេ យើងនៅតែត្រូវការរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលដដែល។

### ទំនួលខុសត្រូវរបស់សវនករឯករាជ្យ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនទាំងមូល នឹងមិនមានកំហុសឆ្គងជាសារវន្ត មិនថាដោយសារការក្លែងបន្លំ ឬការភាន់ច្រឡំឡើយ។ ហើយធ្វើការរាយការណ៍របាយការណ៍សវនករដែលរាប់បញ្ចូលទាំងមតិយោបល់របស់យើងខ្ញុំផងដែរ។ ការធានាអះអាងដែលសមហេតុផល គឺការធានាអះអាងកម្រិតខ្ពស់ ប៉ុន្តែមិនមែនធានាអះអាងថាសវនកម្មដែលធ្វើឡើងស្របតាមស្តង់ដាអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា តែងតែរកឃើញរាល់កំហុសជាសារវន្តនោះឡើយ។ ការបំភាន់អាចកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានគេចាត់ទុកថាជាសារវន្ត ប្រសិនបើជាលក្ខណៈបុគ្គលឬជាក្រុមពួកវាអាចជះឥទ្ធិពលដល់ការសម្រេចចិត្តខាងសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដែលផ្អែកលើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ជាផ្នែកមួយនៃសវនកម្មស្របតាមស្តង់ដាអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា យើងអនុវត្តការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈនិងរក្សាការសង្ស័យដែលមានជំនាញវិជ្ជាជីវៈ នៅសវនកម្មទាំងមូល។ យើងក៏:-

ក). កំណត់ និងវាយតម្លៃហានិភ័យនៃភាពមិនត្រឹមត្រូវ ខាងសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មិនថាដោយសារការក្លែងបន្លំ ឬកំហុស។ រៀបចំនិងអនុវត្តនីតិវិធីសវនកម្មឆ្លើយតបទៅនឹងហានិភ័យទាំងនោះនិងទទួលបានភស្តុតាងសវនកម្ម ដែលមានលក្ខណៈគ្រប់គ្រាន់នឹងសមស្រប ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់មតិយោបល់របស់យើង។ ហានិភ័យដែលមិនរកឃើញកំហុសខាងសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំគឺមានភាពខ្ពស់ជាងបណ្តាលមកពីកំហុសឆ្គង ព្រោះការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិត ការកែច្នៃ ការលុបចោលដោយចេតនាការបកស្រាយមិនពិត ឬ ការបំពានក្នុងការគ្រប់គ្រងផ្ទៃក្នុង។

Crowe

**របាយការណ៍របស់សវនករឯករាជ្យសម្រាប់សមាជិកនៃ**
**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក**

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)
(លេខចុះបញ្ជីក្រុមហ៊ុន: 00043909)

**ទំនួលខុសត្រូវរបស់សវនករឯករាជ្យ(តពីទំព័រមុន)**

ខ). ទទួលបានការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុងដែលពាក់ព័ន្ធនឹងសវនកម្ម ដើម្បីរៀបចំនីតិវិធីសវនកម្មដែលសមស្របក្នុងកាលៈទេសៈ ប៉ុន្តែមិនមែនសម្រាប់គោលបំណងនៃការបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។

គ). វាយតម្លៃភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានប្រើនិងភាពសមហេតុផលនៃ ការប៉ាន់ស្មានគណនេយ្យនិងការបង្ហាញដែលពាក់ព័ន្ធដែលធ្វើឡើងដោយអ្នកគ្រប់គ្រង។

ឃ). សន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់ របស់ក្រុមប្រឹក្សាភិបាលនៃមូលដ្ឋានដែលគួរឱ្យព្រួយបារម្ភនៃគណនេយ្យ និងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានថាតើភាពមិនច្បាស់លាស់នៃសារវន្តមានទាក់ទងនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឱ្យមានការសង្ស័យយ៉ាងខ្លាំងចំពោះសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តភាពអាជីវកម្ម។ ប្រសិនបើយើងសន្និដ្ឋានថាមានភាពមិនច្បាស់លាស់នៃសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលទៅក្នុងរបាយការណ៍របស់សវនកររបស់យើងដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានហិរញ្ញវត្ថុ ឬបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិយោបល់សវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍សវនកររបស់យើង។ ទោះយ៉ាងណាព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចបណ្តាលឱ្យក្រុមហ៊ុនបញ្ឈប់និរន្តភាពអាជីវកម្ម។

ង). វាយតម្លៃការបង្ហាញនៃទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួមមានការលាតត្រដាងនិងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលតំណាងឱ្យប្រតិបត្តិការនិងព្រឹត្តិការណ៍មូលដ្ឋានក្នុងលក្ខណៈដែលទទួលបានការបង្ហាញដោយត្រឹមត្រូវ។

យើងបានផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ចស្តីពីបញ្ហាផ្សេងៗ វិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀតដែលមានរួមបញ្ចូលទាំងចំណុចខ្វះខាតក្នុងការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្មរបស់យើង។

Crowe

**របាយការណ៍របស់សវនករឯករាជ្យសំរាប់សមាជិកនៃ**
**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក**

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជា)
(លេខចុះបញ្ជីក្រុមហ៊ុន: 00043909)

**បញ្ហាផ្សេងទៀត**

ការធ្វើសវនកម្មរបស់យើងខ្ញុំគឺក្នុងគោលបំណងបង្ហាញពីទស្សនៈទៅលើមូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុទាំងមូលជារូបិយប័ណ្ណ ដុល្លារអាមេរិក។ ការបំលែងរបាយការណ៍ហិរញ្ញវត្ថុពីដុល្លារអាមេរិកទៅជាខ្មែររៀលដោយប្រើអត្រាបិទ និង អត្រាមធ្យមនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ បានបង្ហាញឡើងក្នុងគោលបំណងវិភាគបន្ថែមហើយមិនមែនជាផ្នែកសំខាន់នៃមូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុនោះទេ។ ការបំលែងនេះមិនត្រូវបានធ្វើសវនកម្មទៅតាមនីតិវិធីដែលបានអនុវត្តទៅលើរបាយការណ៍ហិរញ្ញវត្ថុនោះទេ ហេតុដូច្នេះយើងខ្ញុំមិនបានបញ្ចេញទស្សនៈណាមួយទៅលើការបំលែងនេះឡើយ។

Crowe (KH) Co., Ltd.
ក្រុមហ៊ុនស្នងការគណនេយ្យករជំនាញ

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ក្រូវ (ខេអេច) ឯ.ក CROWE (KH) CO., LTD. KINGDOM OF CAMBODIA

Onn Kien Hoe
អភិបាល
ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ២០២១

របាយការណ៍សវនកម្មស្តីអំពី
របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ២០២០

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)

លេខចុះបញ្ជីក្រុមហ៊ុន: 00043909

### របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

| | កំណត់សម្គាល់ | ២០២០<br>ដុល្លារអាមេរិក | ២០២០<br>ខ្មែរពាន់រៀល |
|---|---|---|---|
| **ទ្រព្យសកម្ម** | | | |
| សាច់ប្រាក់ក្នុងដៃ | 5 | 9,203 | 37,226 |
| សមតុល្យនៅធនាគារនានា | 6 | 61,196 | 247,538 |
| ឥណទាន និង បុរេប្រទាន | 7 | 1,532,654 | 6,199,585 |
| ទ្រព្យសកម្មផ្សេងៗ | 8 | 42,293 | 171,075 |
| ប្រាក់តម្កល់តាមច្បាប់ នៅធនាគារជាតិនៃ កម្ពុជា | 9 | 100,000 | 404,500 |
| គ្រឿងបរិក្ខារ | 10 | 67,291 | 272,192 |
| ទ្រព្យអរូបី | 11 | 67,472 | 272,924 |
| **ទ្រព្យសកម្មសរុប** | | 1,880,109 | 7,605,041 |
| **បំណុល និង មូលធន** | | | |
| **បំណុល** | | | |
| កម្ចី | 12 | 200,000 | 809,000 |
| ទ្រព្យអកម្មផ្សេងៗ | 13 | 26,369 | 106,663 |
| **បំណុលសរុប** | | 226,369 | 915,663 |
| **មូលធន** | | | |
| ដើមទុន | 14 | 2,000,000 | 8,00,000 |
| ទុនបម្រុងបទប្បញ្ញត្តិ | 15 | 5,657 | 22,882 |
| ខាតបង្គរ | | (351,917) | (1,423,504) |
| លំអៀងពីអត្រាប្តូរប្រាក់ | | - | 90,000 |
| **មូលធនសរុប** | | 1,653,740 | 6,689,378 |
| **បំណុល និង មូលធនសរុប** | | 1,880,109 | 7,605,041 |

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)

លេខចុះបញ្ជីក្រុមហ៊ុន: 00043909

## របាយការណ៍លទ្ធផលពេញលេញ

សំរាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

| | កំណត់សម្គាល់ | ២០២០<br>ដុល្លារអាមេរិក | ២០២០<br>ខ្មែរពាន់រៀល |
|---|---|---|---|
| ចំណូលការប្រាក់ | 16 | 161,570 | 653,551 |
| ចំណាយការប្រាក់ | 17 | 3,451 | 13,959 |
| **ចំណេញដុល** | | 158,119 | 639,591 |
| ចំណូលផ្សេងៗ | 18 | 10,002 | 40,458 |
| ចំណាយលើប្រាក់ខែបុគ្គលិក | 19 | 303,892 | 1,229,243 |
| រំលស់លើទ្រព្យរូបី | 10 | 21,082 | 85,277 |
| រំលស់លើទ្រព្យអរូបី | 11 | 15,208 | 61,516 |
| ចំណាយលើប្រតិបត្តិការផ្សេងៗ | 20 | 162,822 | 658,615 |
| សំវិធានធនសម្រាប់ឥណទានបាត់បង់ | 7 | 9,767 | 39,508 |
| ខាត/ ចំណេញមុនបង់ពន្ធ | | (344,650) | (1,394,109) |
| ចំណាយពន្ធលើប្រាក់ចំនេញ | 21 | 1,610 | 6,512 |
| ខាតបន្ទាប់ពីបង់ពន្ធ | | (346,260) | (1,400,622) |
| ប្រាក់ចំណូលផ្សេងទៀត | | - | - |
| ខាតក្នុងឆ្នាំ | | (346,260) | (1,400,622) |

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)
លេខចុះបញ្ជីក្រុមហ៊ុន: 00043909

### របាយការណ៍បំរែបំរួលមូលធន

សំរាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

| | កំណត់សម្គាល់ | មូលធន<br>ដុល្លារអាមេរិក | ទុនបម្រុងបទប្បញ្ញត្តិ<br>ដុល្លារអាមេរិក | ខាតបង្គរ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|
| សមតុល្យថ្ងៃទី ១ ខែ មករា ឆ្នាំ ២០២០ | | 2,000,000 | - | - | 2,000,000 |
| ខាតសុទ្ធសម្រាប់ការិយបរច្ឆេទ | | - | - | (346,260) | (346,260) |
| ផ្ទេរ | | - | 5,657 | (5,657) | - |
| សមតុល្យថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ | | 2,000,000 | 5,657 | (351,917) | 1,653,740 |

| | កំណត់សម្គាល់ | មូលធន<br>ខ្មែរពាន់រៀល | ទុនបម្រុងបទប្បញ្ញត្តិ<br>ខ្មែរពាន់រៀល | ខាតបង្គរ<br>ខ្មែរពាន់រៀល | ទឹកប្រាក់លំអៀងបង្គរពីការប្តូរប្រាក់<br>ខ្មែរពាន់រៀល | សរុប<br>ខ្មែរពាន់រៀល |
|---|---|---|---|---|---|---|
| សមតុល្យថ្ងៃទី១ ខែ មករា ឆ្នាំ ២០២០ | | 8,000,000 | - | - | - | 8,000,000 |
| ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | | - | - | (1,400,622) | - | (1,400,622) |
| ផ្ទេរ | | - | 22,882 | (22,882) | - | - |
| លំអៀងពីអត្រាប្តូរប្រាក់ | | - | - | | 90,000 | 90,000 |
| សមតុល្យថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ | | 8,000,000 | 22,882 | (1,423,504) | 90,000 | 6,689,378 |

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)

លេខចុះបញ្ជីក្រុមហ៊ុន: 00043909

## របាយការណ៍បំរែបំរួលសាច់ប្រាក់

សំរាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

| | កំណត់សម្គាល់ | ២០២០<br>ដុល្លារអាមេរិក | ២០២០<br>ខ្មែរពាន់រៀល |
|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | |
| ខាតមុនបង់ពន្ធប្រាក់ចំណេញ | | (344,650) | (1,394,109) |
| និយ័តភាព៖ | | | |
| សំវិធានធនសម្រាប់ឥណទានបាត់បង់ | | 9,767 | 39,508 |
| រំលស់លើគ្រឿងបរិក្ខារ | 10 | 21,082 | 85,277 |
| រំលស់លើទ្រព្យអរូបី | 11 | 15,208 | 61,516 |
| ចំណាយការប្រាក់ | 17 | 3,451 | 13,959 |
| ខាតមុនបម្រែបម្រួលទុនបង្វិល | | (295,142) | (1,193,849) |
| ការកើនឡើងនិងការថយចុះនៃ៖ | | | |
| - ឥណទាននិងបុរេប្រទាន | 7 | (1,542,421) | (6,239,093) |
| - ទ្រព្យសកម្មផ្សេង | 8 | (42,293) | (171,075) |
| - ប្រាក់បញ្ញើតាមច្បាប់ | 9 | (100,000) | (404,500) |
| - បំណុលផ្សេងៗ | 13 | 26,369 | 106,663 |
| **សាច់ប្រាក់ដែលត្រូវបានប្រើក្នុងសកម្មភាព ប្រតិបត្តិការ** | | (1,953,487) | (7,901,854) |
| ពន្ធប្រាក់ចំណេញដែលត្រូវបង់ | | (1,610) | (6,512) |
| **សាច់ប្រាក់ដែលត្រូវបានប្រើក្នុងសកម្មភាពប្រតិបត្តិការសុទ្ធ** | | (1,955,097) | (7,908,366) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | |
| ការទិញគ្រឿងបរិក្ខារ | 10 | (88,373) | (357,467) |
| ការទិញទ្រព្យអរូបី | 11 | (82,680) | (334,444) |
| **សាច់ប្រាក់សុទ្ធដែលត្រូវបានក្នុងសកម្មភាពវិនិយោគ** | | (171,053) | (691,911) |
| **លំហូរសាច់ប្រាក់សម្រាប់សកម្មភាពហិរញ្ញវត្ថុ** | | | |
| ការថយចុះនៃសាច់ប្រាក់សុទ្ធ | 12 | 200,000 | 809,000 |
| ការប្រាក់បានបង់ | 17 | (3,451) | (13,959) |
| ចំណូលពីការចេញភាគហ៊ុនធម្មតា | 14 | 2,000,000 | 8,000,000 |
| **ប្រាក់សុទ្ធពីសកម្មភាពហិរញ្ញវត្ថុ** | | 2,196,549 | 8,795,041 |

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)

លេខចុះបញ្ជីក្រុមហ៊ុន: 00043909

### របាយការណ៍បំរែបំរួលសាច់ប្រាក់

សំរាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

| | | |
|---|---|---|
| ការថយចុះនៃសាច់ប្រាក់សុទ្ធ | 70,399 | 194,764 |
| សាច់ប្រាក់នៅដើមការិយបរិច្ឆេទក្នុងឆ្នាំ | - | - |
| បម្រែបម្រួលអត្រាប្តូរប្រាក់ | - | 90,000 |
| សាច់ប្រាក់ចុងគ្រា | 70,399 | 284,764 |

### សាច់ប្រាក់និងសមមូលសាច់ប្រាក់មានដូចខាងក្រោម:

| | កំណត់សម្គាល់ | ២០២០ ដុល្លារអាមេរិក | ២០២០ ខ្មែរពាន់រៀល |
|---|---|---|---|
| សាច់ប្រាក់ក្នុងដៃ | 5 | 9,203 | 37,226 |
| សមតុល្យនៅធនាគារនានា | 6 | 61,196 | 247,538 |
| សាច់ប្រាក់សុទ្ធ និងសាច់ប្រាក់សម មូលសរុប | | 70,399 | 284,764 |

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក**
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)
លេខចុះបញ្ជីក្រុមហ៊ុនៈ 00043909

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ**
សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

## ១. ព័ត៌មានទូទៅ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក (ពីនេះតទៅហៅថា "ក្រុមហ៊ុន") ត្រូវបានបង្កើតឡើងនៅព្រះរាជាណាចក្រកម្ពុជា និងបានចុះបញ្ជីការនៅក្រសួងពាណិជ្ជកម្មនៅថ្ងៃទី 21 ខែ មិថុនា ឆ្នាំ 2019 ក្រោមបញ្ជីលេខ 00043909 និងចាប់ផ្តើមប្រតិបត្តិការអាជីវកម្មរបស់ខ្លួននៅ ខែ វិច្ឆិកា ឆ្នាំ 2019។ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណប្រកបអាជីវកម្ម ពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី 22 ខែ តុលា ឆ្នាំ 2019។

ការិយាល័យចុះបញ្ជីៈ ផ្ទះលេខ J137 ផ្លូវលំ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យបច្ចុប្បន្នៈ ផ្ទះលេខ J137 ផ្លូវលំ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុម័តឲ្យបោះផ្សាយដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០២១។

## ២. សកម្មភាពចម្បងរបស់ក្រុមហ៊ុន

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺផ្តល់សេវាកម្ម ក្នុងវិស័យហិរញ្ញវត្ថុ និងការផ្តល់សេវាពាក់ព័ន្ធ ហិរញ្ញវត្ថុ នៅក្នុងប្រទេសកម្ពុជា។
មិនមានការប្រែប្រួលទៅលើសកម្មភាពចម្បងរបស់ក្រុមហ៊ុន នោះទេនៅក្នុងកំឡុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ៣. មូលដ្ឋានគ្រឹះនៃការរៀបចំ

ទាំងនេះគឺជារបាយការណ៍ហិរញ្ញវត្ថុដំបូងរបស់ក្រុមហ៊ុនដែលបានរៀបចំដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិរបស់កម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម("CIFRSs for SMEs")។

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក**
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)
លេខចុះបញ្ជីក្រុមហ៊ុន: 00043909

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ**
សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

## ៣. មូលដ្ឋានគ្រឹះនៃការរៀបចំ (តពីទំព័រមុន)

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើងតាមសន្ទតិកម្មថ្លៃដើម និងត្រូវបានកែប្រែដើម្បីដាក់ បញ្ចូលមូលដ្ឋានវាយតម្លៃផ្សេងទៀតដែលត្រូវបានបង្ហាញ នៅក្នុងផ្នែកផ្សេងទៀតក្រោមគោលនយោបាយគណនេយ្យសំខាន់ៗ និងអនុលោមទៅតាមបទប្បញ្ញាត្តិទាំងឡាយរបស់ធនាគារជាតិនៃកម្ពុជា និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិរបស់កម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម("CIFRSs for SMEs") ។

នេះគឺជារបាយការណ៍ហិរញ្ញវត្ថុដំបូងរបស់ក្រុមហ៊ុនដែលបានរៀបចំតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិរបស់កម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម ("CIFRSs for SMEs") ។

នៅក្នុងឆ្នាំហិរញ្ញវត្ថុមុនរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំទៅតាមបទប្បញ្ញាត្តិទាំងឡាយរបស់ធនាគារជាតិនៃកម្ពុជាស្តង់ដារគណនេយ្យកម្ពុជា និងការអនុវត្តក្នុងវិស័យឧស្សាហកម្មមីក្រូហិរញ្ញវត្ថុ។

ការផ្លាស់ប្តូរទៅ CIFRSs for SMEs ត្រូវបានរាប់បញ្ចូលដោយអនុលោមតាមផ្នែកទី 35 "ការផ្លាស់ប្តូរទៅ CIFRSs for SMEs" ដោយថ្ងៃទី 1 ខែមករា ឆ្នាំ 2018 ជាកាលបរិច្ឆេទផ្លាស់ប្តូរ។ សម្រាប់របាយការណ៍លទ្ធផលពេញលេញ ត្រូវបានរៀបចំដោយផ្អែកលើគោលការណ៍គណនេយ្យដូចដែលបានពិពណ៌នានៅក្នុងកំណត់សម្គាល់ទី 4 ដែលត្រូវបានអនុវត្ត ចំពោះរបាយការណ៍ហិរញ្ញវត្ថុផ្សេងទៀតរួមទាំងព័ត៌មានប្រៀបធៀបផ្សេងៗដែលបានបង្ហាញក្នុងរបាយការណ៍។ ផលប៉ះពាល់នៃការផ្លាស់ប្តូរពី CAS ទៅជា CIFRS សម្រាប់សហគ្រាសធុនតូចនិងមធ្យមត្រូវបានកំណត់នៅក្នុងកំណត់សម្គាល់ 21 ទៅរបាយការណ៍ហិរញ្ញវត្ថុ។

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ

### ៤.១ សុភវិនិច្ឆ័យសំខាន់ដែលថ្នាក់គ្រប់គ្រងប្រើប្រាស់ក្នុងគោលនយោបាយគណនេយ្យ និង ការប៉ាន់ស្មានលើភាពមិនច្បាស់លាស់

អ្នកគ្រប់គ្រងជឿជាក់ថាគ្មានការសន្មត់សំខាន់ៗណាមួយទាក់ទងនឹងកង្វល់ទៅអនាគត និងប្រភពគន្លឹះផ្សេងទៀតនៃភាពមិនច្បាស់លាស់នៃការប៉ាន់ស្មាននៅកាលបរិច្ឆេទនៃការរាយការណ៍ដែលមានហានិភ័យគួរឱ្យកត់សម្គាល់ក្នុងការបង្កឱ្យមានការកែសំរួលទៅនឹងតម្លៃយោងនៃទ្រព្យសកម្ម និងទ្រព្យអកម្មក្នុងកំឡុងឆ្នាំហិរញ្ញវត្ថុបន្ទាប់ ក្រៅពីការបង្ហាញខាងក្រោម:-

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក**
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)
លេខចុះបញ្ជីក្រុមហ៊ុន: 00043909

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ**
សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### ៤.១ សុភវិនិច្ឆ័យសំខាន់ដែលថ្នាក់គ្រប់គ្រងប្រើប្រាស់ក្នុងគោលនយោបាយគណនេយ្យ និង ការប៉ាន់ស្មានលើភាពមិនច្បាស់លាស់ (តពីទំព័រមុន)

#### (ក) សំវិធានធនលើឥណទាន និងបុរេប្រទាន

សំវិធានធនដែលខាតបង់ត្រូវបានទទួលស្គាល់នៅពេលដែលមានភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុចុះខ្សោយ។ គណៈគ្រប់គ្រងត្រួតពិនិត្យឡើងវិញជាពិសេសនូវឥណទាន និងបុរេប្រទាន ហើយវិភាគអំពីអាយុកាលរបស់ពួកគេ ប្រវត្តិបំណុលមិនល្អ ការផ្តោតអារម្មណ៍របស់អតិថិជន ភាពគួរឱ្យទុកចិត្តរបស់អតិថិជន និន្នាការសេដ្ឋកិច្ចបច្ចុប្បន្ន និងការផ្លាស់ប្តូរលក្ខខណ្ឌទូទាត់អតិថិជននៅពេលធ្វើការវិនិច្ឆ័យដើម្បីវាយតម្លៃភាពគ្រប់គ្រាន់នៃ សម្រាប់ការទទួលស្គាល់សំវិធានធនដែលខាតបង់។ កន្លែងដែលមានភស្តុតាងបញ្ជាក់ពីការចុះខ្សោយទៅលើចំនួន និង ពេលវេលានៃលំហូរសាច់ប្រាក់នាពេលអនាគតត្រូវបានប៉ាន់ប្រមាណ ដោយផ្អែកលើបទពិសោធន៍នៃការបាត់បង់ប្រវត្តិសាស្ត្រ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានលក្ខណៈហានិភ័យឥណទានស្រដៀងគ្នា។ ប្រសិនបើការរំពឹងទុក ខុសគ្នាពីការប៉ាន់ស្មាន ភាពខុសគ្នាបែបនេះនឹងជះឥទ្ធិពលដល់តម្លៃយោងរបស់អ្នកដែលត្រូវទទួល។

#### (ខ) ពន្ធលើប្រាក់ចំណេញ

យោងតាមប្រតិបត្តិការនិងការគណនាយ៉ាងជាក់លាក់ដែល កំណត់ពន្ធចុងក្រោយអាចខុសគ្នាពីការប៉ាន់ស្មានដំបូងនោះ ក្រុមហ៊ុនទទួលស្គាល់បំណុលពន្ធផ្អែក លើចំណេះដឹងរបស់ខ្លួនអំពីច្បាប់ពន្ធនិងការប៉ាន់ប្រមាណពីចរិកលក្ខណៈរបស់ពន្ធដែល កំពុងកើតមានក្នុងអាជីវកម្មរបស់ខ្លួន។បើនៅចុងគ្រាលទ្ធផលចុងក្រោយនៃភាពខុសគ្នាពី ចំនួនទឹកប្រាក់ដែលត្រូវបានទទួលស្គាល់ដំបូងនោះនឹង ជះឥទ្ធិពលដល់ការចំណាយពន្ធលើប្រាក់ចំណូលនិងសមតុល្យពន្ធពន្យារ។

ការធ្វើវិសោធនកម្មត្រូវបានធ្វើឡើងក្នុងការអនុវត្តគោលនយោបាយគណនេយ្យ។

គណៈគ្រប់គ្រងជឿជាក់ថាមិនមានករណីណាមួយនៃការអនុវត្តការវិនិច្ឆ័យសំខាន់ក្នុងការអនុវត្តគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនដែល នឹង ជះឥទ្ធិពលយ៉ាងខ្លាំងទៅលើចំនួនទឹកប្រាក់ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក**
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)
លេខចុះបញ្ជីក្រុមហ៊ុន: 00043909

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ**
សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

---

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### ៤.២ រូបិយវត្ថុ និងរូបិយប័ណ្ណបរទេស

#### (ក) រូបិយវត្ថុ និង អត្រា

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានបង្ហាញនៅក្នុងរូបិយប័ណ្ណ នៃបរិយាកាសសេដ្ឋកិច្ចបឋមនៅក្នុងក្រុមហ៊ុនដែលប្រតិបត្តិការដែលជារូបិយប័ណ្ណគោល។ របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជាដុល្លារអាមេរិក ("ដុល្លារអាមេរិក") ដែលជារូបិយប័ណ្ណ មុខងារនិងបង្ហាញរបស់ក្រុមហ៊ុន។

ការបំលែងទឹកប្រាក់ពីដុល្លារអាមេរិកទៅជាខ្មែររៀលត្រូវបាន បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដើម្បីអនុលោមតាមច្បាប់គណនេយ្យ និងសវនកម្ម ចុះថ្ងៃទី 11 ខែ មេសា ឆ្នាំ 2016 ដោយប្រើអត្រាបិទ និងអត្រាជាមធ្យម នាចុងការិយបរិច្ឆេទដែលបានប្រកាសដោយអគ្គនាយកដ្ឋានពន្ធដារនៃកម្ពុជា។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជាខ្មែររៀលដោយផ្អែកលើ អត្រាប្តូរប្រាក់ក្នុង ១ ដុល្លារអាមេរិក ដូចក្នុងតារាងខាងក្រោម៖

| | 2020 |
|---|---|
| អត្រាចុងគ្រា | 4,045 |

ចំនួនទឹកប្រាក់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានកាត់ខ្ទង់ជាពាន់សម្រាប់ប្រាក់ដុល្លារ និង ប្រាក់រៀល ។

#### (ខ) ប្រតិបត្តិការរូបិយប័ណ្ណបរទេស និង សមតុល្យ

ប្រតិបត្តិការរូបិយប័ណ្ណបរទេសត្រូវបានប្តូរទៅជារូបិយប័ណ្ណមុខងារ នៅលើការទទួលស្គាល់ដំបូងដោយប្រើអត្រាប្តូរប្រាក់នៅកាលបរិច្ឆេទប្រតិបត្តិការ។ នៅចុងបញ្ចប់នៃកាលបរិច្ឆេទនៃរបាយការណ៍រូបិយវត្ថុបរទេសចំពោះទ្រព្យសកម្ម និងបំណុលត្រូវបាន កំណត់ឡើង វិញតាមអត្រាប្តូរប្រាក់នៃកាលបរិច្ឆេទនោះ។

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក**
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)
លេខចុះបញ្ជីក្រុមហ៊ុន: 00043909

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ**
សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### ៤.២ រូបិយវត្ថុ និងរូបិយប័ណ្ណបរទេស (តពីទំព័រមុន)

#### (ខ) ប្រតិបត្តិការណ៍រូបិយប័ណ្ណបរទេស និង សមតុល្យ (តពីទំព័រមុន)

ទ្រព្យសកម្មនិងបំណុលដែលមិនមែនជារូបិយវត្ថុ មិនត្រូវបានវាយតម្លៃឡើងវិញជារូបិយប័ណ្ណបរទេសទេ នៅចុងបញ្ចប់នៃរបាយការណ៍។

ភាពខុសគ្នានៃការប្តូររូបិយប័ណ្ណបរទេសដែលកើតឡើងពីការទូទាត់នៃ រូបិយវត្ថុ ឬលើការប្តូររូបិយវត្ថុ ឡើងវិញត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញឬខាតក្នុងការិយបរិច្ឆេទដែលវាកើតឡើង។

### ៤.៣ ឧបករណ៍ហិរញ្ញវត្ថុ

#### (ក) ការទទួលស្គាល់ និងការវាស់វែងដំបូង

ទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុត្រូវបាន ទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនៅពេលដែលក្រុមហ៊ុនបានក្លាយជាភាគីនៃ កិច្ចសន្យារបស់ឧបករណ៍ទាំងនេះ។

ឧបករណ៍ហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ដំបូង ក្នុងតម្លៃប្រតិបត្តិការរួមទាំងថ្លៃដើមប្រតិបត្តិការ។ ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុឬបំណុលហិរញ្ញវត្ថុដែលត្រូវបានវាស់ជាបន្តបន្ទាប់ដោយតម្លៃតាមរយៈប្រាក់ចំណេញឬខាត ថ្លៃដើមប្រតិបត្តិការត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញឬខាតនៅពេលដែលកើតឡើង។

ការរៀបចំបង្កើតប្រតិបត្តិការហិរញ្ញប្បទានអាចមាន ប្រសិនបើការទូទាត់ត្រូវបានពន្យារពេលលើសពីលក្ខខណ្ឌអាជីវកម្មធម្មតា។នៅក្រោមប្រតិបត្តិការហិរញ្ញប្បទាន ទ្រព្យសកម្មហិរញ្ញវត្ថុ ឬ បំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងតាមតម្លៃបច្ចុប្បន្ននៃការទូទាត់នាពេលអនាគតដែលបានបញ្ចុះអត្រាការប្រាក់ទីផ្សារសម្រាប់ឧបករណ៍បំណុលស្រដៀងគ្នាដូចដែលបានកំណត់នៅការទទួលស្គាល់ដំបូង។ ការកែតម្រូវតម្លៃបច្ចុប្បន្នគឺ អាស្រ័យទៅលើការទទួលស្គាល់នូវប្រាក់ចំណេញ ឬ ខាតភ្លាមៗ ប្រសិនបើតម្លៃបច្ចុប្បន្ននោះបង្ហាញដោយតម្លៃដកស្រង់ក្នុងទីផ្សារសម្រាប់កំណត់សម្គាល់នូវទ្រព្យសកម្មឬបំណុលឬផ្អែកទៅលើបច្ចេកទេសវាយតម្លៃដែលប្រើប្រាស់នូវទិន្នន័យពី ការអង្កេតលើទីផ្សារ បើមិនដូច្នោះទេ ភាពខុសគ្នាត្រូវបានគិតលើប្រាក់ចំណេញ ឬ ខាត តាមវិធីសាស្ត្រ រំលស់ស្មើភាគ ទៅលើលក្ខខណ្ឌនៃកិច្ចសន្យានៃឧបករណ៍ហិរញ្ញវត្ថុ។

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក**

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)
លេខចុះបញ្ជីក្រុមហ៊ុន: 00043909

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ**

សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

---

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### ៤.៣ ឧបករណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

#### (ខ) ការវាស់វែងជាបន្តបន្ទាប់

ឧបករណ៍បំណុលដែលត្រូវបានចាត់ថ្នាក់ជា ទ្រព្យសកម្មរយៈពេលខ្លីឬទ្រព្យអកម្មរយៈពេលខ្លីត្រូវបានវាស់វែងតាមចំនួនទឹកប្រាក់ដែលមិនទាន់រាប់បញ្ចូលជាសាច់ប្រាក់ ឬ ការពិចារណាផ្សេងទៀតដែលរំពឹងថានឹងត្រូវបង់ ឬទទួលលុះត្រាតែការរៀបចំនេះមានប្រសិទ្ធិភាពជាការរៀបចំហិរញ្ញប្បទាន។ ឧបករណ៍បំណុលផ្សេងទៀតត្រូវបានវាស់វែងដោយចំណាយរំលស់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

ក្រៅពីអ្វីទាំងអស់ខាងលើ ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងតាមតម្លៃបច្ចុប្បន្នជាមួយនឹងការផ្លាស់ប្តូរ តម្លៃបច្ចុប្បន្នដែលទទួលស្គាល់នៅក្នុងប្រាក់ចំណេញឬការខាត។

#### (គ) ការមិនទទួលស្គាល់

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬផ្នែកណាមួយរបស់វាមិនត្រូវបានគេទទួលស្គាល់នៅពេលដែលសិទ្ធិចំពោះសាច់ប្រាក់ហូរចេញពីទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានផុតកំណត់ ឬទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានផ្ទេរទៅឱ្យភាគីផ្សេងទៀតដោយមិនរក្សាការគ្រប់គ្រង ឬហានិភ័យទាំងអស់នៃទ្រព្យសកម្ម។ការមិនទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាភាពខុសគ្នារវាងតម្លៃយោងនិងតម្លៃដែលទទួលបាន (សន្មត់ថារាប់បញ្ចូលទាំងបំណុលថ្មី) និងត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញឬខាត។

បំណុលហិរញ្ញវត្ថុឬផ្នែកណាមួយរបស់វា ត្រូវបានគេមិនទទួលស្គាល់នៅពេលដែលកាតព្វកិច្ចដែលបានបញ្ជាក់នៅក្នុងកិច្ចសន្យាត្រូវបានរំសាយលុបចោលឬផុតកំណត់។

ការកែប្រែយ៉ាងច្រើននៃលក្ខខណ្ឌ នៃបំណុលហិរញ្ញវត្ថុដែលមានស្រាប់ត្រូវបានរាប់បញ្ចូលជាការបំបាត់បំណុលហិរញ្ញវត្ថុដើមនិងការទទួលស្គាល់បំណុលហិរញ្ញវត្ថុថ្មី។ យោងតាមការមិនទទួលស្គាល់នៃបំណុលហិរញ្ញវត្ថុ ភាពខុសគ្នារវាងតម្លៃយោងនៃបំណុលហិរញ្ញវត្ថុដែលលុបបំបាត់ ឬផ្ទេរទៅឱ្យភាគីផ្សេងទៀតនិងចាត់ទុកថាជាការចំណាយ(រួមទាំងទ្រព្យសកម្មមិនមែនជាសាច់ប្រាក់ផ្ទេរ ឬបំណុលដែលបានសន្មត់)ត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញឬខាត។

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក**

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)

លេខចុះបញ្ជីក្រុមហ៊ុន: 00043909

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ**

សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### ៤.៣ ស្ថាប័នហិរញ្ញវត្ថុ (តពីទំព័រមុន)

#### ឃ) ភាគហ៊ុនធម្មតា

ភាគហ៊ុនធម្មតាត្រូវបានចាត់ថ្នាក់ជាដើមទុន និងត្រូវបានកត់ត្រាជាចំណូលដែលទទួលបានសុទ្ធពីការដកថ្លៃដើមប្រតិបត្តិការដោយផ្ទាល់។

ភាគលាភលើភាគហ៊ុនធម្មតាត្រូវបានទទួលស្គាល់ថា ជាបំណុលនៅពេលដែលត្រូវបានអនុម័តសម្រាប់ភាពសមស្រប។

### ៤.៤ គ្រឿងបរិក្ខារ

គ្រឿងបរិក្ខារទាំងអស់ត្រូវបានវាស់ដំបូងដោយតម្លៃដើម។ ការចំណាយរួមមានការចំណាយដែលត្រូវបានផ្ទេរដោយផ្ទាល់ទៅនឹងការទិញទ្រព្យសកម្ម និងការចំណាយផ្សេងទៀតដោយផ្ទាល់ដែលនាំឱ្យទ្រព្យសកម្មទៅជាលក្ខខណ្ឌការងារសម្រាប់ការប្រើប្រាស់របស់ខ្លួន។

បន្ទាប់ពីការកត់សម្គាល់ដំបូង គ្រឿងបរិក្ខារទាំងអស់ត្រូវបានបញ្ជាក់តាមតម្លៃការចំណាយរំលស់បង្គរ និងការខាតបង់លើឱនភាព។

ការចំណាយជាបន្តបន្ទាប់ត្រូវបានបញ្ចូលក្នុងតម្លៃយោងរបស់ទ្រព្យ ឬត្រូវបានទទួលស្គាល់ថាជាទ្រព្យសកម្មដាច់ដោយឡែក បើសិនវាអាចជាអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដែលជាប់ពាក់ព័ន្ធនឹងធាតុដែលនឹងហូរចូលទៅក្រុមហ៊ុនហើយតម្លៃរបស់ធាតុអាចត្រូវបានវាស់វែងបាន។ តម្លៃយោងនៃសាច់ប្រាក់ដែលត្រូវបានជំនួសត្រូវបានគេលែងទទួលស្គាល់។

ការរំលស់ ត្រូវបានគិតក្នុងប្រាក់ចំណេញឬខាតហើយត្រូវបានគណនាតាមវិធីសាស្ត្រ រំលស់ថយជាលំដាប់ ដើម្បីលុបចោលចំនួនរំលស់ នៃទ្រព្យសកម្មក្នុងរយៈពេលដែលមាន អាយុកាលដែលបានប៉ាន់ ប្រមាណ។ អត្រារំលស់ប្រចាំឆ្នាំដែលត្រូវបានប្រើប្រាស់សម្រាប់គណនារំលស់គឺ៖

| | |
|---|---|
| ការកែលំអរភតិសន្យា | 20% |
| គ្រឿងសង្ហារឹម និងលំអរ | 25% |
| គ្រឿងបរិក្ខារ | 25% |
| បរិក្ខារកុំព្យូទ័រ | 25% |
| យានយន្ត | 25% |

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក**
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)
លេខចុះបញ្ជីក្រុមហ៊ុន: 00043909

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ**
សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### ៤.៤ គ្រឿងបរិក្ខារ (តពីទំព័រមុន)

វិធីសាស្ត្ររំលស់អាយុកាល និងតម្លៃសំណល់នឹងត្រូវបានពិនិត្យឡើងវិញប្រសិនបើមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ចាប់តាំងពីកាលបរិច្ឆេទរបាយការណ៍ចុងក្រោយបំផុតនៅក្នុងគំរូដែល ក្រុមហ៊ុនរំពឹងថានឹងប្រើប្រាស់អត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតរបស់ទ្រព្យសកម្ម។ ការផ្លាស់ប្តូរណាមួយត្រូវបានគេគណនាថាជាការផ្លាស់ប្តូរនៅក្នុងការប៉ាន់ស្មានគណនេយ្យ។

ការចំណេញឬការបាត់បង់ណាមួយដែលកើតឡើងពីការលក់ទ្រព្យ និងបរិក្ខារត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬ ខាត។

### ៤.៥ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី តំណាងដោយថ្លៃដើមដំបូងដែលបាន កើតឡើងពីការទិញប្រព័ន្ធគ្រប់គ្រងទិន្នន័យធនាគារ។

បន្ទាប់ពីការទទួលស្គាល់ដំបូង ទ្រព្យសកម្មអរូបីត្រូវបានកត់ត្រាដោយយកថ្លៃដើមដករំលស់បង្គរព្រមទាំងការខាតបង្គរផ្សេងៗទៀត។

ទ្រព្យសកម្មអរូបីត្រូវបានវាយតម្លៃថាមានអាយុកាលច្បាស់លាស់ហើយត្រូវបានរំលស់ទៅ តាមអាយុរបស់ ប្រព័ន្ធគ្រប់គ្រងទិន្នន័យធនាគារតាមវិធីសាស្ត្រ រំលស់ថេរ។ ទ្រព្យសកម្មអរូបីក៏ត្រូវបានវាយតម្លៃ ផងដែរសម្រាប់ការខូចខាតនៅពេលដែលមានសុច្ចនាករណ៍បញ្ជាក់ថាពួកវាត្រូវមានការខូចខាត។ ការិយបរិច្ឆេទ នីមួយៗរបស់ទ្រព្យសកម្មអរូបីត្រូវបានរំលស់ដូចខាងក្រោម៖

| | |
|---|---|
| ទ្រព្យអរូបិយ | 20% |

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក**
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)
លេខចុះបញ្ជីក្រុមហ៊ុន: 00043909

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ**
សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### ៤.៦ ឱនភាព

#### (ក) ឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ

រាល់ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ (លើកលែងតែទ្រព្យសកម្មហិរញ្ញវត្ថុដែល បានវាស់វែងតម្លៃតាមរយៈប្រាក់ចំណេញឬខាត) ត្រូវបានគេវាយតម្លៃសម្រាប់ឱនភាពនៅកាលបរិច្ឆេទរបាយការណ៍នីមួយៗនៅពេលមានភស្តុតាងនៃឱនភាព។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមតម្លៃរំលស់ ការខាតបង់ទៅលើឱនភាពគឺជាការខុសគ្នារវាងចំនួនទឹកប្រាក់ជាក់ស្តែងនៃទ្រព្យសកម្មហិរញ្ញវត្ថុ និង តម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ដែលបានប៉ាន់ស្មាននៅអត្រាដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុ។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបាន វាស់វែងដោយយកថ្លៃដើមដកឱនភាពការបាត់បង់ឱនភាពនេះគឺជាភាពខុសគ្នារវាងតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុនិងការប៉ាន់ស្មានអំពីចំនួនដែលត្រូវបានទទួលសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ ប្រសិនបើវាត្រូវបានលក់នៅកាលបរិច្ឆេទនៃរបាយការណ៍។

ការខាតបង់លើឱនភាពត្រូវបាន ទទួលស្គាល់ក្នុងរបាយការណ៍ចំណេញឬខាតបង់ភ្លាមៗ។

ប្រសិនបើក្នុងកំឡុងពេលជាបន្តបន្ទាប់បរិមាណ នៃការខាតបង់លើឱនភាពបានថយចុះហើយការថយចុះនេះអាចត្រូវបានទាក់ទង ដោយចេតនាចំពោះព្រឹត្តិការណ៍ដែលកើតឡើងបន្ទាប់ពីការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់។ ការខាតបង់លើឱនភាពនៃតម្លៃដែលត្រូវបានទទួលស្គាល់ ពីមុននឹងត្រូវបានដាក់ត្រឡប់ទៅនឹងវិសាលភាពនៃតម្លៃជាក់ស្តែងរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមិនលើសពីការតម្លៃរំលស់របស់ខ្លួននៅកាលបរិច្ឆេទផ្លាស់ប្តូរ។ ចំនួនទឹកប្រាក់នៃការផ្លាស់ប្តូរការថយចុះត្រូវបានកត់ត្រាក្នុងរបាយការណ៍ចំណេញឬខាត។

<u>ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន</u>

នៅថ្ងៃទី 1 ខែធ្នូ ឆ្នាំ 2017 ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសថ្មីលេខ B7-017-344 ស្តីពីចំណាត់ថ្នាក់ហានិភ័យ និងការផ្តល់ប្រាក់កម្ចីសម្រាប់ការធានាការទទួលស្គាល់ការវាស់វែង ការផ្តល់ និងការរាយការណ៍ពីឱនភាពសម្បទានរបស់ស្ថាប័ន។

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក**
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)
លេខចុះបញ្ជីក្រុមហ៊ុន: 00043909

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ**
សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

---

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### ៤.៦ ឱនភាព

#### (ក) ឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ

សម្បទាននៅក្រោមប្រកាសនេះត្រូវបានកំណត់ថាជាប្រាក់កម្ចី និងផលិតផលហិរញ្ញវត្ថុដទៃទៀតដែលបានរាយការណ៍នៅលើតារាងតុល្យការ ឬក្រៅតារាងតុល្យការដែលត្រូវបានផ្តល់ដោយស្ថាប័នមួយទៅឱ្យភាគីមួយទៀត ដែលផ្តល់ហានិភ័យដល់ហានិភ័យឥណទានចំពោះស្ថាប័ននេះ។

នៅថ្ងៃទី 16 ខែ កុម្ភៈ ឆ្នាំ 2018 ធនាគារជាតិ នៃ កម្ពុជា បានចេញផ្សាយសារាចរលេខ B7-018-001 ដែលបញ្ជាក់ពីការអនុវត្តប្រកាសស្តីពីកម្រិតហានិភ័យឥណទាន និងការផ្តល់ឱនភាពនៃសំវិធានធន។

យោងតាមសារាចរថ្មីនិងអំឡុងពេលអន្តរកាល (គិតចាប់ពីថ្ងៃទី 1 ខែធ្នូ ឆ្នាំ 2017 ដល់ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2018) ក្រុមហ៊ុនត្រូវធ្វើការគណនាឱនភាពលើឥណទានអាក្រក់ និងជាប់សង្ស័យស្របតាមបទប្បញ្ញត្តិដែលគ្រឹះស្ថានត្រូវបានចាត់ថ្នាក់ជា 5 ថ្នាក់ជាមួយនឹងអត្រាផ្តល់ដូចខាងក្រោម :

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃដែលផុតកំណត់ | សំវិធានធន |
|---|---|---|
| **១. សំវិធានធនទូទៅ** | | |
| ឥណទានរយៈពេលខ្លី(តិចជាង១ឆ្នាំ) | | |
| ធម្មតា | ពី០ថ្ងៃទៅ១៤ថ្ងៃ | ១% |
| ឥណទានរយៈពេលវែង(ច្រើនជាង១ឆ្នាំ) | | |
| ធម្មតា | ពី០ថ្ងៃទៅ២៩ថ្ងៃ | ១% |

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក**

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)

លេខចុះបញ្ជីក្រុមហ៊ុន: 00043909

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ**

សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

**៤. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)**

**៤.៦ ឱនភាព (តពីទំព័រមុន)**

**(ក) ឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ (តពីទំព័រមុន)**

**២. សំវិធានធនជាក់លាក់**

| ឥណទានរយៈពេលខ្លី(តិចជាង១ឆ្នាំ) | | |
|---|---|---|
| បំណុលឃ្លាំមើល | ពី១៥ថ្ងៃទៅ៣០ថ្ងៃ | ៣% |
| ក្រោមស្តង់ដារ | ពី៣១ថ្ងៃទៅ៦០ថ្ងៃ | ២០% |
| សង្ស័យ | ពី៦១ថ្ងៃទៅ៩០ថ្ងៃ | ៥០% |
| បាត់បង់ | ពី៩១ថ្ងៃឡើងទៅ | ១០០% |

| ឥណទានរយៈពេលវែង(ច្រើនជាង១ឆ្នាំ) | | |
|---|---|---|
| បំណុលឃ្លាំមើល | ពី៣០ថ្ងៃទៅ៨៩ថ្ងៃ | ៣% |
| ក្រោមស្តង់ដារ | ពី៩០ថ្ងៃទៅ១៧៩ថ្ងៃ | ២០% |
| សង្ស័យ | ពី១៨០ថ្ងៃទៅ៣៥៩ថ្ងៃ | ៥០% |
| បាត់បង់ | ពី៣៦០ថ្ងៃឡើងទៅ | ១០០% |

បទប្បញ្ញត្តិដែលត្រូវអនុវត្តត្រូវបានអនុវត្តទៅលើគ្រប់ទីកន្លែង និងក្រៅតារាងតុល្យការរបស់ធនាគារនិងស្ថាប័នហិរញ្ញវត្ថុ។

ប្រកាសនេះតម្រូវឱ្យមានការប្រៀបធៀបបទប្បញ្ញត្តិ ស្តីពីការថយចុះតម្លៃដោយផ្អែកលើ CIFRS សម្រាប់សហគ្រាសធុនតូចនិងមធ្យម។ ក្នុងករណីបទប្បញ្ញត្តិដែលបានគណនាស្របតាមប្រកាសមានកម្រិតទាបជាង ការខាតបង់សំវិធានធនដែលបានកំណត់ ដោយផ្អែកលើ CIFRS សម្រាប់សហគ្រាសធុនតូចនិងមធ្យម ក្រុមហ៊ុន នឹងទទួលស្គាល់ការ ខាតបង់សំវិធានធនដែលបានកំណត់ស្របតាម CIFRS សម្រាប់សហគ្រាស ធុនតូចនិងមធ្យម ។ ក្នុងករណីបទប្បញ្ញត្តិខ្ពស់ជាង ការបាត់បង់សំវិធានធន ក្រុមហ៊ុននឹងទទួលស្គាល់ការបាត់បង់សំវិធានធនដែលបានកំណត់ស្របតាម CIFRS សម្រាប់សហគ្រាសធុនតូចនិងមធ្យម និងផ្ទេរភាពខុសគ្នាពីប្រាក់ចំណូលដែលបានរក្សាទុកទៅជាទុនបម្រុងបទប្បញ្ញត្តិ។ក្រុមហ៊ុនបានបង្ហាញនូវទុនបម្រុងបទប្បញ្ញត្តិនៅក្នុង សេចក្តីថ្លែងការណ៍អំពីបម្រែបម្រួលមូលធន ។

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក**
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)
លេខចុះបញ្ជីក្រុមហ៊ុន: 00043909

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ**
សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

---

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### ៤.៦ ឱនភាព (តពីទំព័រមុន)

#### (ក) ឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ (តពីទំព័រមុន)

ប្រាក់កម្ចីដែលមិនអាចទារបាន ឬចំណែកនៃប្រាក់កម្ចី ដែលត្រូវបានចាត់ថ្នាក់ថាត្រូវបានលុបចោលបន្ទាប់ពីការពិចារណាលើ តម្លៃដែលអាចសម្រេចបាននៃវត្ថុបញ្ចាំ ប្រសិនបើនៅពេលធ្វើការវិនិច្ឆ័យពីការគ្រប់គ្រងមិនមានលទ្ធភាពនៃការសងឡើងវិញ។ ការទទួលបានមកវិញនូវប្រាក់កម្ចី ដែលបានលុបចោលកាលពីពេលមុន ត្រូវបានបង្ហាញថាជាប្រាក់ចំណូលផ្សេងទៀតនៅក្នុងរបាយការណ៍នៃប្រាក់ចំណេញឬខាត។

ការវាយតម្លៃលើភាពគ្រប់គ្រាន់នៃសំវិធានធនសម្រាប់ការខាតបង់ប្រាក់កម្ចីគឺផ្អែកលើការវិនិច្ឆ័យរបស់អ្នកគ្រប់គ្រងពីចំនួនទឹកប្រាក់ដែលចាំបាច់ដើម្បីរក្សាសំវិធានធន នៅកម្រិតសមស្របដើម្បីទទួលស្គាល់ការខាតបង់។

គោលនយោបាយរបស់សំវិធានធន គឺផ្អែកលើបទពិសោធន៍របស់អ្នកគ្រប់គ្រងទាក់ទងទៅនឹងទំហំដែលបែងចែក បទពិសោធន៍នៃការខាតបង់ពីមុន លក្ខខណ្ឌសេដ្ឋកិច្ចបច្ចុប្បន្ន និងផលប៉ះពាល់របស់ពួកវាលើអតិថិជនម្នាក់ៗនិងការអនុវត្តប្រាក់កម្ចីបុគ្គលទាក់ទងនឹងកិច្ចសន្យា។ ប្រាក់កម្ចីអាក្រក់នឹងត្រូវបានលុបចោលនៅពេលដែលវាមើលឃើញថាសមស្រប។

#### (ខ) ឱនភាពនៃទ្រព្យដែលមិនមែនជាទ្រព្យសកម្មហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យ ក្រៅពីវត្ថុដែលមានផ្អែកទី២៧ ឱនភាពទ្រព្យមិនអនុវត្តត្រូវបានពិនិត្យឡើងវិញទេរបាយការណ៍ហិរញ្ញវត្ថុនីមួយៗ នៅរយៈពេលចុងគ្រាសម្រាប់ការ ចុះអន់ថយនៅពេលដែលការវាយតម្លៃលើឱនភាពនៃតម្លៃប្រចាំឆ្នាំមានកាតព្វកិច្ច ឬមានការបង្ហាញថាទ្រព្យអាចចុះ។

ការថយចុះត្រូវបានវាស់ដោយប្រៀបធៀបតម្លៃទ្រព្យសកម្មជាមួយបរិមាណ ដែលអាចយកមកវិញបាន។ នៅពេលដែលចំនួនទ្រព្យសកម្មនៃទ្រព្យសកម្មមានលើសពីចំនួនដែលអាច សន្សំបានទ្រព្យសកម្មត្រូវបានកត់ត្រាទុករហូតដល់ចំនួនទឹកប្រាក់ដែលអាចយកមកវិញបានហើយការខាតបង់លើភាពចុះថយត្រូវបានទទួលស្គាល់។

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក**
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)
លេខចុះបញ្ជីក្រុមហ៊ុន: 00043909

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ**
សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### ៤.៦ ឱនភាព (តពីទំព័រមុន)

#### (ខ) ឱនភាពនៃទ្រព្យដែលមិនមែនជាទ្រព្យសកម្មហិរញ្ញវត្ថុ(តពីទំព័រមុន)

ចំនួនទ្រព្យសកម្មដែល អាចស្តារឡើងវិញបានគឺខ្ពស់ជាងតម្លៃទ្រព្យសកម្មរបស់ការចំណាយតិចជាងការលក់ និង តម្លៃដែលកំពុងប្រើប្រាស់របស់ខ្លួនដែលត្រូវបានវាស់ដោយ យោងទៅលើលំហូរសាច់ប្រាក់នាពេលអនាគត ដោយបញ្ចុះអត្រាពន្ធ ដែលឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារ បច្ចុប្បន្ន នៃទឹកប្រាក់និងហានិភ័យជាក់លាក់ចំពោះទ្រព្យសកម្ម។ នៅពេលដែលវា មិនអាចប៉ាន់ស្មានពីចំនួនដែលអាចទាញយកបាននៃទ្រព្យសកម្មនីមួយៗ ក្រុមហ៊ុននឹងកំណត់ចំនួនទឹកប្រាក់ដែលអាចយកមកវិញបានពីទ្រព្យសកម្មដែលមាន។ សុទិដ្ឋិនិយមដែលទទួលបាន នៅក្នុងការរួមបញ្ចូលគ្នានៃអាជីវកម្ម គឺចាប់ពីកាលបរិច្ឆេទនៃការទទួលបានការចរចារ ទៅកាន់អង្គភាពបង្កើតសាច់ប្រាក់របស់ក្រុមហ៊ុនដែលត្រូវបានរំពឹងថានឹងទទួលបានអត្ថប្រយោជន៍ពី ការរួមបញ្ចូលគ្នាដោយមិនគិតថាតើទ្រព្យសកម្មផ្សេងទៀត ឬ បំណុលរបស់អ្នកទទួលបានត្រូវចាត់តាំងទៅអង្គភាពទាំងនោះ។

ការខាតបង់លើឱនភាពត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញឬខាត។

នៅពេលមានការផ្លាស់ប្តូរការប៉ាន់ស្មានដែលត្រូវបានប្រើ ដើម្បីកំណត់ចំនួនទឹកប្រាក់ដែលអាចប្រមូលបានមកវិញ ការកើនឡើងជាបន្តបន្ទាប់នៃចំនួនទឹកប្រាក់ដែលអាចប្រមូលបានមកវិញនៃទ្រព្យសកម្ម ត្រូវបានចាត់ទុកថាជាការបញ្ច្រាសនៃការខាតបង់នៃឱនភាពពីមុន និងត្រូវបានគេទទួលស្គាល់ជាតម្លៃយោងនៃទ្រព្យសកម្មដែលនឹងត្រូវបានគេកំណត់ (ដករំលស់ចេញ) ពុំមានការទទួលស្គាល់លើការខាតបង់លើឱនភាពទេ។ ការបញ្ច្រាសត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញឬខាតភ្លាមៗ។

### ៤.៧ សាច់ប្រាក់ និង សាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានសាច់ប្រាក់និងសមតុល្យសាច់ប្រាក់ក្នុងធនាគារប្រាក់បញ្ញើនៅធនាគារដែលមានកាលវសាន្តនៅពេលតម្កល់ដំបូងមានរយៈពេល ៣ខែ ឬតិចជាងកាលបរិច្ឆេទនៃការទទួលបាន រួមទាំងសាច់ប្រាក់នៅលើដៃ សមតុល្យដែលមិនបានដាក់កម្រិតជាមួយធនាគារជាតិ នៃ កម្ពុជា និង សមតុល្យជាមួយធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត។

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក**
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)
លេខចុះបញ្ជីក្រុមហ៊ុន: 00043909

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ**
សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### ៤.៨ ប្រាក់តំកល់តាមច្បាប់នៅធនាគារជាតិនៃកម្ពុជា

សមតុល្យនៅធនាគារជាតិនៃកម្ពុជារួមបញ្ចូលប្រាក់បញ្ញើតម្កល់តាមច្បាប់ ត្រូវបានកត់ត្រាតាមតម្លៃដើម។ ប្រាក់បញ្ញើតម្កល់តាមច្បាប់ត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជាស្របតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានកំណត់ជាភាគរយ នៃដើមទុនអប្បបរមានិងប្រាក់បញ្ញើរបស់អតិថិជនដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។ សាច់ប្រាក់នេះមិនអាចប្រើក្នុងហិរញ្ញប្បទានដល់ប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុនទេ ដូច្នេះហើយមិនត្រូវបានចាត់ទុកថាជាផ្នែកនៃសាច់ប្រាក់និងសមមូលសាច់ប្រាក់សម្រាប់គោលបំណងនៃលំហូរសាច់ប្រាក់ទេ។

### ៤.៩ ភតិសន្យា

រាល់កិច្ចសន្យាជួលទាំងឡាយណាដែលមិនផ្ទេរទៅឱ្យក្រុមហ៊ុននូវរាល់ហានិភ័យ និង រង្វាន់ដែលកើតមានចំពោះម្ចាស់កម្មសិទ្ធិ ត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិការហើយទ្រព្យ ដែលបានជួលមិនត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

ការទូទាត់ភតិសន្យាប្រតិបត្តិការត្រូវបានទទួលស្គាល់ថាជាការចំណាយលើប្រាក់ចំណេញឬខាតលើវិធីសាស្រ្ត រំលស់ថេរ ក្នុងរយៈពេលជួល។

### ៤.១០ សំវិធានធន

សំវិធានធននឹងត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចបច្ចុប្បន្ន (ស្របច្បាប់ឬមានលក្ខណៈស្ថាបនា) ជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងមកនៅពេលដែលអាចមានលំហូរចេញនៃប្រភពធនធានសេដ្ឋកិច្ចដែលទទួលបានផលប្រយោជន៍សេដ្ឋកិច្ច នឹងត្រូវបានទាមទារដើម្បីដោះស្រាយកាតព្វកិច្ចនោះ ហើយនៅពេលដែលការប៉ាន់ស្មានដែលអាចទុកចិត្តបាន នៃចំនួនទឹកប្រាក់អាចត្រូវបានធ្វើឡើង។ សំវិធានធនត្រូវបានពិនិត្យឡើងវិញនៅចុងបញ្ចប់នៃរយៈពេលរាយការណ៍នីមួយៗ និងត្រូវបានកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីការប៉ាន់ស្មានដ៏ល្អបំផុតនាពេលបច្ចុប្បន្ន។ នៅពេលដែលផលប៉ះពាល់នៃតម្លៃពេលវេលានៃប្រាក់មានសារវន្ត សំវិធានធនគឺជាតម្លៃបច្ចុប្បន្ននៃការចំណាយដែលបានប៉ាន់ប្រមាណដែលត្រូវការដើម្បីទូទាត់កាតព្វកិច្ច។ អត្រាបញ្ចុះតម្លៃ គឺជាអត្រាពន្ធមុនដែលបង្ហាញពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃពេលវេលានៃប្រាក់ និង ហានិភ័យជាក់លាក់ចំពោះបំណុល។ ការដកការបញ្ចុះតម្លៃត្រូវបានទទួលស្គាល់ថាជាការ ចំណាយការប្រាក់ក្នុងប្រាក់ចំណេញឬការខាត។

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក**
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)
លេខចុះបញ្ជីក្រុមហ៊ុន: 00043909

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ**
សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### ៤.១១ អត្ថប្រយោជន៍បុគ្គលិក

ប្រាក់ឈ្នួល ប្រាក់បៀវត្ស ប្រាក់ការឈប់សំរាកប្រចាំឆ្នាំ ប្រាក់លើកទឹកចិត្តនិងការចូលរួមចំណែកសន្តិសុខសង្គមត្រូវបានវាស់វែងតាមមូលដ្ឋានដែលមិនត្រូវបានរាប់បញ្ចូល ហើយត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬ ខាតក្នុងរយៈពេលដែលពាក់ព័ន្ធទៅនឹងសេវាកម្មដែលបានបំពេញដោយបុគ្គលិកនៃក្រុមហ៊ុន។

### ៤.១២ ពន្ធលើប្រាក់ចំណេញ

#### (ក) ពន្ធចរន្ត

ទ្រព្យសកម្មនិងបំណុលពន្ធចរន្តត្រូវបានរំពឹងទុកជាចំនួនពន្ធលើប្រាក់ចំណូលដែលអាចប្រមូលមកវិញបានឬត្រូវបង់ជូនអាជ្ញាធរពន្ធដារ។ ពន្ធចរន្តត្រូវបានវាស់វែងដោយប្រើអត្រាពន្ធនិងច្បាប់ពន្ធដែលត្រូវបានអនុម័ត ឬ អនុម័តយ៉ាងសំខាន់នៅចុងបញ្ចប់នៃការិយបរិច្ឆេទរបស់របាយការណ៍ និងត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាតលើកលែងតែពន្ធដែលទាក់ទងទៅនឹងធាតុដែលបានទទួលស្គាល់ក្រៅពី ប្រាក់ចំណេញ ឬខាត (របាយការណ៍លទ្ធផលពេញលេញឬនៅក្នុងមូលធនដោយផ្ទាល់)។

#### (ខ) ពន្ធពន្យារ

ពន្ធពន្យារ ត្រូវបានទទួលស្គាល់ដោយប្រើវិធីសាស្ត្របំណុលសម្រាប់ភាពខុសគ្នាបណ្តោះអាសន្នទាំងអស់ក្រៅពីការកើតឡើងពីសុច្ឆន្ទៈ ឬ ពីការទទួលស្គាល់ដំបូងនៃទ្រព្យសម្បត្តិ ឬ ការទទួលខុសត្រូវក្នុងប្រតិបត្តិការដែលមិនមែនជាការរួមបញ្ចូលគ្នានៃអាជីវកម្ម និងនៅពេលប្រតិបត្តិការនោះមិនប៉ះពាល់ដល់ប្រាក់ចំណេញគណនេយ្យ ក៏មិនមែនជាប្រាក់ចំណេញជាប់ពន្ធ។

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក**
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)
លេខចុះបញ្ជីក្រុមហ៊ុន: 00043909

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ**
សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### ៤.១២ ពន្ធលើប្រាក់ចំណេញ (តពីទំព័រមុន)

#### (ខ) ពន្ធពន្យារ (តពីទំព័រមុន)

ពន្ធពន្យារលើទ្រព្យសកម្ម និង ទ្រព្យអកម្មត្រូវបានកំណត់ដោយប្រើអត្រាពន្ធដែលរំពឹងទុកដើម្បី អនុវត្តទៅលើចំណេញជាប់ពន្ធនៅក្នុងឆ្នាំដែលភាពខុសគ្នាទាំងនោះត្រូវបានរំពឹងថានឹងស្តារមកវិញ ឬ សងវិញផ្អែកលើអត្រាដែលបានអនុម័ត ឬ ត្រូវបានអនុម័តនៅរាល់ចុងការិយបរិច្ឆេទនៃ របាយការណ៍។

ពន្ធពន្យារសកម្មត្រូវបានទទួលស្គាល់រាល់គ្រប់ភាពខុសគ្នាបណ្តោះអាសន្នដែលអាចកាត់កងបានការយោងទៅមុខនៃការខាតពន្ធដែលមិនបានប្រើប្រាស់ ក្នុងករណីដែលវាទំនងថាចំណេញដែលបង់ពន្ធ អាចប្រើប្រាស់សម្រាប់ទូទាត់ភាពខុសគ្នាបណ្តោះអាសន្ន ដែលអាចកាត់កងបានការយោងទៅមុខនៃការខាតពន្ធដែលមិនបានប្រើប្រាស់អាចយកមកប្រើប្រាស់បាន។ តម្លៃយោងរបស់ពន្ធពន្យារសកម្មដែលទទួលស្គាល់ត្រូវបានពិនិត្យឡើងវិញនៅចុងការិយបរិច្ឆេទនីមួយៗ និងបានកាត់បន្ថយទៅនឹងវិសាលភាពដែលមិនអាចទទួលបានអត្ថប្រយោជន៍ពន្ធដែលពាក់ព័ន្ធ។

#### (គ) អាករលើតម្លៃបន្ថែម (VAT)

ប្រាក់ចំណូល ចំណាយ និងទ្រព្យសកម្មត្រូវបានទទួលស្គាល់ដោយដកអាករលើតម្លៃបន្ថែមចេញលើកលែងតែអាករលើតម្លៃបន្ថែមក្នុងការទិញទ្រព្យសកម្ម ឬ សេវាកម្មដែលមិនអាចទារមកវិញបានពីអាជ្ញាធរពន្ធដារ ត្រូវបានរួមបញ្ចូលជាផ្នែកមួយនៃថ្លៃដើមនៃទ្រព្យសកម្មដែលបានទទួល ឬជាផ្នែកមួយនៃចំណាយ ដែលអាចអនុវត្តបាន។

លើសពីនេះ គណនីដែលត្រូវទារ និងគណនីដែលត្រូវសង ត្រូវបានបញ្ជាក់ផងដែរជាមួយនឹងចំនួនអាករលើតម្លៃបន្ថែមដែលមាន (ដែលអាចអនុវត្តបាន)។

ចំនួនទឹកប្រាក់សុទ្ធនៃអាករលើតម្លៃបន្ថែមដែលអាចទទួលបានវិញ ឬ ត្រូវបង់ទៅអាជ្ញាធរពន្ធដារ នៅចុងការិយបរិច្ឆេទនៃរបាយការណ៍ ត្រូវបានរាប់បញ្ចូលក្នុងគណនីត្រូវទារផ្សេងៗ ឬ គណនីត្រូវសងផ្សេងៗ។

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក**

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)

លេខចុះបញ្ជីក្រុមហ៊ុន: 00043909

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ**

សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### ៤.១២ ពន្ធលើប្រាក់ចំណេញ (តពីទំព័រមុន)

ពន្ធចរន្ត និងពន្ធពន្យារត្រូវបានទទួលស្គាល់នៅក្នុងការជាប់ទាក់ទងទៅនឹងប្រតិបត្តិការមូលដ្ឋានទាំងការចំណេញ ឬ ខាត និងប្រាក់ចំណូលពេញលេញផ្សេងៗទៀត ឬដោយផ្ទាល់នៅក្នុងមូលធន។ ពន្ធពន្យារដែលកើតឡើងពីការរួមបញ្ចូលគ្នានៃអាជីវកម្មត្រូវបានកែតម្រូវទៅលើសុច្ឆន្ទៈ ឬអវិជ្ជមាន។

ពន្ធចរន្តសកម្មនិងបំណុលពន្ធសកម្មឬពន្ធពន្យារសកម្ម និងបំណុលពន្ធពន្យារត្រូវបានទូទាត់នៅពេលដែលមានការអនុញ្ញាតត្រឹមត្រូវតាមច្បាប់ដើម្បីកំណត់ពន្ធពន្យារសកម្មប្រឆាំងនឹងបំណុលពន្ធពន្យារ និងនៅពេលដែលពន្ធពន្យារបានទាក់ទងទៅនឹងអង្គភាពជាប់ពន្ធដូចគ្នា (ឬក៏អង្គភាពពន្ធផ្សេងៗ ប៉ុន្តែពួកគេមានបំណងដើម្បីទូទាត់ពន្ធចរន្តសកម្ម និងបំណុលពន្ធសកម្មលើមូលដ្ឋានសុទ្ធ) និងអាជ្ញាធរប្រមូលពន្ធដូចគ្នា។

### ៤.១៣ ចំណូលពីកិច្ចសន្យាជាមួយអតិថិជន និងចំណូលផ្សេងៗ

ប្រាក់ចំណូលពីកិច្ចសន្យាជាមួយអតិថិជនត្រូវបានវាស់វែង ផ្អែកលើការពិចារណាដែលបានបញ្ជាក់នៅក្នុងកិច្ចសន្យាជាមួយអតិថិជនជាថ្នូរទៅនឹងការលក់សេវាទៅអតិថិជន និងពន្ធលើសេវាកម្ម ការបង្វិលត្រឡប់មកវិញ ការបង្វិលប្រាក់ និងការបញ្ចុះតម្លៃ។ ក្រុមហ៊ុនទទួលស្គាល់ប្រាក់ចំណូលនៅពេលដែលបានបំពេញសេវាកម្មរួចរាល់ទៅអតិថិជន។ ដោយយោងទៅតាមខ្លឹមសារនៃកិច្ចសន្យាប្រាក់ចំណូលត្រូវបានទទួលស្គាល់ នៅពេលដែលកាតព្វកិច្ចនៃការអនុវត្តត្រូវបានពេញចិត្តដែលអាចជាចំណុចមួយនៅក្នុងពេលវេលាឬលើសម៉ោង។

**(ក) ចំណូលការប្រាក់**

ចំណូលការប្រាក់ ត្រូវបានទទួលស្គាល់តាមមូលដ្ឋានបង្គរ ដោយផ្អែកលើវិធីសាស្ត្រការប្រាក់ ប្រកបដោយប្រសិទ្ធភាព។ ចំណូលការប្រាក់លើឥណទាននិងបុរេប្រទានប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារត្រូវបានទទួលស្គាល់ជាមូលដ្ឋានបង្គរប្រចាំថ្ងៃ។ ការប្រាក់លើប្រាក់កម្ចីមិនដំណើរការ ត្រូវបានកត់ត្រាទុកជាការប្រាក់ជាជាងការទទួលស្គាល់ជាប្រាក់ចំណូលរហូតដល់ទទួលបានប្រាក់សុទ្ធ។

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក**
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)
លេខចុះបញ្ជីក្រុមហ៊ុន: 00043909

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ**
សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

---

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### ៤.១៣ ចំណូលពីកិច្ចសន្យាជាមួយអតិថិជន និងចំណូលផ្សេងៗ (តពីទំព័រមុន)

#### (ខ) ចំណូលសេវា និងកម្រៃជើងសារ

ថ្លៃសេវា និងកម្រៃជើងសារបៀបចំកម្ចីត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលនៅពេលដែលលក្ខខណ្ឌទាំងអស់ត្រូវបានបំពេញ។

ថ្លៃសេវាកម្ម ថ្លៃដំណើរការ និង ប្រាក់ចំណូលពីប្រតិបត្តិការផ្សេងៗទៀតត្រូវបានទទួលស្គាល់នៅពេលសិទ្ធិទទួលបានការទូទាត់ត្រូវបានបង្កើតឡើង។

## ៥. សាច់ប្រាក់នៅក្នុងដៃ

| | ២០២០ ដុល្លារអាមេរិក | ២០២០ ខ្មែរពាន់រៀល |
|---|---|---|
| ដុល្លារអាមេរិក | 8,500 | 34,383 |
| ខ្មែររៀល | 703 | 2,843 |
| | 9,203 | 37,226 |

## ៦. សមតុល្យជាមួយធនាគារផ្សេងៗ

| | ២០២០ ដុល្លារអាមេរិក | ២០២០ ខ្មែរពាន់រៀល |
|---|---|---|
| គណនីចរន្ត | | |
| ធនាគារ កាណាឌីយ៉ា | 59,966 | 242,562 |
| ធនាគារជាតិនៃកម្ពុជា | 1,230 | 4,975 |
| | 61,196 | 247,538 |
| តាមរូបិយប័ណ្ណ | | |
| ដុល្លារអាមេរិក | 202 | 817 |
| ខ្មែរពាន់រៀល | 60,994 | 246,721 |
| | 61,196 | 247,538 |

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក**

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)

លេខចុះបញ្ជីក្រុមហ៊ុន: 00043909

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ**

សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

## ៧. ឥណទាន និង បុរេប្រទាន

| | ២០២០ | ២០២០ |
|---|---|---|
| | ដុល្លារអាមេរិក | ខ្មែរពាន់រៀល |
| **ឥណទានជាឯកត្តជន** | | |
| ឥណទានសំណង់ | 1,542,421 | 6,239,093 |
| ឥណទានប្រើប្រាស់ | 1,542,421 | 6,239,093 |
| សំវិធានធនដែលបាត់បង់ | (9,767) | (39,058) |
| ឥណទាន និងបុរេប្រទានសុទ្ធ | 1,532,654 | 6,199,585 |

ការប្រែប្រួលសំវិធានធនដែលបាត់បង់មានដូចតទៅ ៖

| | ២០២០ | ២០២០ |
|---|---|---|
| | ដុល្លារអាមេរិក | ខ្មែរពាន់រៀល |
| ថ្ងៃទី២១ មិថុនា ២០១៩(ថ្ងៃចុះបញ្ជី) | - | - |
| ផ្ទេរទៅក្នុងរបាយការណ៍ចំណេញឬ ខាត | (9,767) | (39,058) |
| លំអៀងពីអត្រាប្តូរប្រាក់ | - | - |
| សមតុល្យនៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០ | (9,767) | (39,058) |

ការវិភាគបន្ថែមលើឥណទាន និង បុរេប្រទាន មានដូចតទៅ ៖

| | ២០២០ | ២០២០ |
|---|---|---|
| | ដុល្លារអាមេរិក | ខ្មែរពាន់រៀល |
| (ក) ភាគតាមកាលកំណត់សង៖ | | |
| ពី ៧ខែទៅ ១ឆ្នាំ | - | - |
| លើសពី ១ឆ្នាំទៅ ៣ឆ្នាំ | - | - |
| លើសពី ៣ឆ្នាំទៅ ៥ឆ្នាំ | - | - |
| លើសពី ៥ឆ្នាំទៅ ៧ឆ្នាំ | 129,652 | 524,443 |
| លើសពី ៧ឆ្នាំទៅ ១៥ឆ្នាំ | 1,412,769 | 5,714,650 |
| | 1,542,421 | 6,239,093 |

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក**

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)

លេខចុះបញ្ជីក្រុមហ៊ុន: 00043909

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ**

សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

## ៧. ឥណទាន និង បុរេប្រទាន (តពីទំព័រមុន)

| | ២០២០ ដុល្លារអាមេរិក | ២០២០ ខ្មែរពាន់រៀល |
|---|---|---|
| (ខ)វិភាគតាមចំណាត់ថ្នាក់ឥណទាន ៖ | | |
| ឥណទានធម្មតា៖ | | |
| - មានវត្ថុធានា | 1,537,971 | 6,221,093 |
| - ពុំមានវត្ថុធានា | 4,450 | 18,000 |
| ឥណទានឃ្លាំមើល៖ | | |
| - មានវត្ថុធានា | - | - |
| - ពុំមានវត្ថុធានា | - | - |
| ឥណទានក្រោមស្តង់ដារ៖ | | |
| - មានវត្ថុធានា | - | - |
| - ពុំមានវត្ថុធានា | - | - |
| ឥណទានសង្ស័យ៖ | | |
| - មានវត្ថុធានា | - | - |
| - ពុំមានវត្ថុធានា | - | - |
| ឥណទានបាត់បង់៖ | | |
| - មានវត្ថុធានា | - | - |
| - ពុំមានវត្ថុធានា | - | - |
| | 1,542,421 | 6,239,093 |

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក**
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)
លេខចុះបញ្ជីក្រុមហ៊ុន: 00043909

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ**
សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

## ៧. ឥណទាន និង បុរេប្រទាន (តពីទំព័រមុន)

| | ២០២០<br>ដុល្លារអាមេរិក | ២០២០<br>ខ្មែរពាន់រៀល |
|---|---|---|
| (គ) វិភាគតាមប្រភេទរូបិយប័ណ្ណ ៖ | | |
| ដុល្លារអាមេរិក | 1,537,971 | 6,221,093 |
| ខ្មែររៀល | 4,450 | 18,000 |
| | 1,542,421 | 6,239,093 |
| (ឃ) វិភាគតាមការស្នាក់នៅ ៖ | | |
| និវាសនជន | 1,542,421 | 6,239,093 |
| (ង) វិភាគទំនាក់ទំនង ៖ | | |
| សម្ព័ន្ធញាតិ | 4,450 | 18,000 |
| ពុំមែនសម្ព័ន្ធញាតិ | 1,537,971 | 6,221,093 |
| | 1,542,421 | 6,239,093 |
| (ច) វិភាគតាមវិស័យសេដ្ឋកិច្ច ៖ | | |
| ប្រើប្រាស់ផ្ទាល់ខ្លួន | 1,542,421 | 6,239,093 |
| (ឆ) វិភាគតាមហានិភ័យ ៖ | | |
| ពុំមានហានិភ័យធំ | - | - |

| | ២០២០ |
|---|---|
| (ជ) វិភាគអត្រាការប្រាក់ប្រចាំឆ្នាំ៖ | |
| - ឥណទានអតិថិជន | 12% |

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក**

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)

លេខចុះបញ្ជីក្រុមហ៊ុន: 00043909

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ**

សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

---

## ៨. ទ្រព្យសកម្មផ្សេងៗ

| | ២០២០ ដុល្លារអាមេរិក | ២០២០ ខ្មែរពាន់រៀល |
|---|---:|---:|
| ការប្រាក់ដែលត្រូវទទួល | 16,443 | 66,512 |
| ការបង់ទុកមុនផ្សេងៗ | 12,360 | 49,996 |
| ការទទួលបានផ្សេងៗ | 13,490 | 54,567 |
| | 42,293 | 171,075 |

## ៩. សមតុល្យនៅធនាគារជាតិកម្ពុជា

| | ២០២០ ដុល្លារអាមេរិក | ២០២០ ខ្មែរពាន់រៀល |
|---|---:|---:|
| ប្រាក់តម្កល់តាមច្បាប់ | 100,000 | 404,500 |

ក្រុមហ៊ុនត្រូវបានតម្រូវឲ្យរក្សាការដាក់ប្រាក់តម្កល់ ៥%នៃដើមទុនរបស់ខ្លួនដើម្បីអនុលោមតាម ប្រកាសលេខ B7-00-06 របស់ធនាគារជាតិនៃកម្ពុជាចុះថ្ងៃទី ១១ខែមករា ឆ្នាំ ២០០០ និងប្រកាសលេខ B7-06-209ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០០៦។ ប្រាក់តម្កល់មិនអាចយកទៅប្រើប្រាស់ទៅលើ ប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុននិងត្រូវបានបង្វិលសងវិញ នៅពេលដែលក្រុមហ៊ុនស្ម័គ្រចិត្តរំដោះ សកម្មភាពរបស់ខ្លួនហើយមិនមានបំណុលដាក់ប្រាក់ឡើយ។ ការដាក់ប្រាក់បញ្ញើតាមផ្លូវច្បាប់នេះ គឺជាអត្រា ការប្រាក់ដែលមានអត្រា ១/២ នៃរយៈពេល ៦ ខែដែលកំណត់ដោយធនាគារជាតិនៃកម្ពុជាសម្រាប់ ប្រាក់បញ្ញើ តាមបញ្ញត្តិដែលរក្សាទុកក្នុងលុយរៀលនិង ៣/៨នៃរយៈពេល ៦ខែនៃអត្រា SIBORសម្រាប់ប្រាក់ បញ្ញើតាមបញ្ញត្តិដែលរក្សាទុកក្នុងប្រាក់ដុល្លារអាមេរិក។

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក**

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩)

លេខចុះបញ្ជីក្រុមហ៊ុន: 00043909

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ**

សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

## ១០. គ្រឿងបរិក្ខារ

| | **២១.០៦.២០១៩** | **ការទិញបន្ថែម** | **ការលុបចោល** | **រំលស់ប្រចាំឆ្នាំ** | **៣១.១២.២០២០** |
|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| តម្លៃយោង | | | | | |
| ការកែលំអភតិសន្យា | - | 20,278 | - | (4,367) | 15,911 |
| គ្រឿងសង្ហារឹម និងលំអរ | - | 14,714 | - | (3,801) | 10,913 |
| គ្រឿងបរិក្ខារ | - | 9,101 | - | (2,366) | 6,735 |
| បរិក្ខារកុំព្យូទ័រ | - | 41,931 | - | (10,058) | 31,873 |
| ម៉ូតូ | - | 2,350 | - | (490) | 1,859 |
| | - | 88,373 | | (21,083) | 67,291 |

| | **២១.០៦.២០១៩** | **ការទិញបន្ថែម** | **ការលក់ចេញ** | **រំលស់ប្រចាំឆ្នាំ** | **លំអៀងអត្រាប្តូរប្រាក់** | **៣១.១២.២០២០** |
|---|---|---|---|---|---|---|
| | ខ្មែរពាន់រៀល | ខ្មែរពាន់រៀល | ខ្មែរពាន់រៀល | ខ្មែរពាន់រៀល | ខ្មែរពាន់រៀល | ខ្មែរពាន់រៀល |
| តម្លៃយោង | | | | | | |
